សិក្ខាសាលាលើកស្ទួយ
បន្ថែមទៀត
បន្ថែមទៀត
បន្ថែមទៀត

មាតិកា

អារម្ភកថា ០១

លទ្ធិប្រជាធិបតេយ្យ

គោលបំណង ០៣
- ១. សំនាំដើម ០៤
- ២. របបប្រជាធិបតេយ្យបែបសភានៅព្រះរាជាណាចក្រកម្ពុជា ០៥
  - ២.១. លក្ខណៈនៃរបបប្រជាធិបតេយ្យបែបសភានៅព្រះរាជាណាចក្រកម្ពុជា ០៥
  - ២.២. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ០៦
  - ២.៣. រចនាសម្ព័ន្ធនៃការគ្រប់គ្រងរដ្ឋរបស់ព្រះរាជាណាចក្រកម្ពុជា ០៨
- ៣. ភាពខុសគ្នារវាងការគ្រប់គ្រងបែបផ្តាច់ការ និង ការគ្រប់គ្រងបែបប្រជាធិបតេយ្យ ១០
- ៤. គោលការណ៍សំខាន់ៗនៃរបបប្រជាធិបតេយ្យ ១១
- ៥. ការអធិប្បាយប្រៀបធៀបរវាងលទ្ធិប្រជាធិបតេយ្យ និង ព្រះពុទ្ធសាសនា ១៤
- ៦. ការអធិប្បាយប្រៀបធៀបរវាងរាទេះ និង លទ្ធិប្រជាធិបតេយ្យ ១៦
- ៧. សារប្រយោជន៍នៃលទ្ធិប្រជាធិបតេយ្យ ១៧
- ៨. សេចក្តីបញ្ចប់ ១៨

សំនួរ និង លំហាត់ ២០

ការចូលរួមរបស់យុវជនក្នុងរបបប្រជាធិបតេយ្យ

គោលបំណង ២១
- ១. សំនាំដើម ២២
- ២. និយមន័យការចូលរួម ២៣
- ៣. តួនាទីមួយចំនួនរបស់យុវជនក្នុងការលើកស្ទួយលទ្ធិប្រជាធិបតេយ្យ ២៤
- ៤. ហេតុអ្វីបានជាយុវជនត្រូវចូលរួមក្នុងលទ្ធិប្រជាធិបតេយ្យ? ២៦
- ៥. ហេតុអ្វីបានជាក្រុមយុវជនមានឥទ្ធិពលនៅក្នុងសង្គម? ២៧

រៀបចំដោយ

YOUTH COUNCIL OF CAMBODIA

ឧបត្ថម្ភដោយ

USAID FROM THE AMERICAN PEOPLE
ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិសហរដ្ឋអាមេរិក

IRI
វិទ្យាស្ថានសាធារណរដ្ឋអន្តរជាតិ

រៀបចំដោយ

ក្រុមប្រឹក្សាយុវជនកម្ពុជា
YOUTH COUNCIL OF CAMBODIA

ឧបត្ថម្ភដោយ

USAID
FROM THE AMERICAN PEOPLE
ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិសហរដ្ឋអាមេរិក

IRI
វិទ្យាស្ថានសាធារណរដ្ឋអន្តរជាតិ

មាតិកា

អារម្ភកថា ០១

លទ្ធិប្រជាធិបតេយ្យ

គោលបំណង ០៣
- ១. សំនាំដើម ០៤
- ២. របបប្រជាធិបតេយ្យបែបសភានៅព្រះរាជាណាចក្រកម្ពុជា ០៥
  - ២.១. លក្ខណៈនៃរបបប្រជាធិបតេយ្យបែបសភានៅព្រះរាជាណាចក្រកម្ពុជា ០៥
  - ២.២. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ០៦
  - ២.៣. រចនាសម្ព័ន្ធនៃការគ្រប់គ្រងរដ្ឋរបស់ព្រះរាជាណាចក្រកម្ពុជា ០៨
- ៣. ភាពខុសគ្នារវាងការគ្រប់គ្រងបែបផ្តាច់ការ និង ការគ្រប់គ្រងបែបប្រជាធិបតេយ្យ ១០
- ៤. គោលការណ៍សំខាន់ៗនៃរបបប្រជាធិបតេយ្យ ១១
- ៥. ការអធិប្បាយប្រៀបធៀបរវាងលទ្ធិប្រជាធិបតេយ្យ និង ព្រះពុទ្ធសាសនា ១៤
- ៦. ការអធិប្បាយប្រៀបធៀបរវាងរទេះ និង លទ្ធិប្រជាធិបតេយ្យ ១៦
- ៧. សារប្រយោជន៍នៃលទ្ធិប្រជាធិបតេយ្យ ១៧
- ៨. សេចក្តីបញ្ចប់ ១៨

សំនួរ និង លំហាត់ ២០

ការចូលរួមរបស់យុវជនក្នុងរបបប្រជាធិបតេយ្យ

គោលបំណង ២១
- ១. សំនាំដើម ២២
- ២. និយមន័យការចូលរួម ២៣
- ៣. តួនាទីមួយចំនួនរបស់យុវជនក្នុងការលើកស្ទួយលទ្ធិប្រជាធិបតេយ្យ ២៤
- ៤. ហេតុអ្វីបានជាយុវជនត្រូវចូលរួមក្នុងលទ្ធិប្រជាធិបតេយ្យ? ២៦
- ៥. ហេតុអ្វីបានជាក្រុមយុវជនមានឥទ្ធិពលនៅក្នុងសង្គម? ២៧

ខ. ការពិពណ៌នាទូទៅអំពីប្រភេទនៃថ្នាលដែលត្រូវការ ២៥
ខ.១. ការពិនិត្យមើលដីសិប្បនិម្មិត ឬ អគ្គិសនីជាមុនសិន ២៥
ខ.២. ការរៀបចំដីឡើងវិញ ឬ ការបន្ថែមដីថ្មី ២៨
ខ.៣. ការប្រើប្រាស់ប្រព័ន្ធបង្ហូរទឹក ៣០
ខ.៤. ការប្រើប្រាស់ប្រព័ន្ធបង្ហូរទឹកដែលមានស្រាប់ ៣០
ខ.៤.ក. ការរៀបចំប្រព័ន្ធបង្ហូរទឹកដែលមានស្រាប់ ៣១
ខ.៤.ខ. ការដាក់ប្រព័ន្ធបង្ហូរទឹកថ្មី ៣៣
ខ.៤.គ. ប្រភេទនៃដីដែលត្រូវការប្រព័ន្ធបង្ហូរទឹក ៣៤
ខ.៤.ឃ. ប្រភេទ និងការប្រើប្រាស់ប្រព័ន្ធបង្ហូរទឹក/លក្ខណៈ ៣៤
ខ.៤.ង. ការដាក់ប្រព័ន្ធបង្ហូរទឹកនៅតាមតំបន់ជម្រាល ៣៥
ខ.៤.ច. ប្រភេទ និងការប្រើប្រាស់ប្រព័ន្ធបង្ហូរទឹកសម្រាប់ប្រើប្រាស់ ៣៦
ខ.៤.ឆ. ប្រភេទនៃសម្ភារៈសម្រាប់ធ្វើប្រព័ន្ធបង្ហូរទឹក ៣៦
ខ.៤.ជ. ការដាក់ប្រព័ន្ធបង្ហូរទឹកនៅតាមតំបន់ជម្រាល ៣៧
ខ.៤.ឈ. ការដាក់ប្រព័ន្ធបង្ហូរទឹកនៅតាមតំបន់ដែលមានដីឥដ្ឋ ៣៨
ខ.៤.ញ. ការដាក់ប្រព័ន្ធបង្ហូរទឹកនៅតាមតំបន់ដែលមានដីខ្សាច់ ៣៨
ខ.៤.ដ. ការដាក់ប្រព័ន្ធបង្ហូរទឹកនៅតាមតំបន់ដែលមានដីឥដ្ឋ ៣៩
ខ.៤.ឋ. ការដាក់ប្រព័ន្ធបង្ហូរទឹកនៅតាមតំបន់ដែលមានដីខ្សាច់ ៣៩
ខ.៤.ឌ. ការដាក់ប្រព័ន្ធបង្ហូរទឹកនៅតាមតំបន់ដែលមានដីឥដ្ឋ ៤០
ខ.៤.ឍ. ការដាក់ប្រព័ន្ធបង្ហូរទឹកនៅតាមតំបន់ដែលមានដីខ្សាច់ ៤០
ខ.៤.ណ. ការដាក់ប្រព័ន្ធបង្ហូរទឹកនៅតាមតំបន់ដែលមានដីឥដ្ឋ ៤០
ខ.៤.ត. ការដាក់ប្រព័ន្ធបង្ហូរទឹកនៅតាមតំបន់ដែលមានដីខ្សាច់ ៤០
ខ.៤.ថ. ការដាក់ប្រព័ន្ធបង្ហូរទឹកនៅតាមតំបន់ដែលមានដីឥដ្ឋ ៤០
ខ.៤.ទ. ការដាក់ប្រព័ន្ធបង្ហូរទឹកនៅតាមតំបន់ដែលមានដីខ្សាច់ ៤០
ខ.៤.ធ. ការដាក់ប្រព័ន្ធបង្ហូរទឹកនៅតាមតំបន់ដែលមានដីឥដ្ឋ ៤០
ខ.៤.ន. ការដាក់ប្រព័ន្ធបង្ហូរទឹកនៅតាមតំបន់ដែលមានដីខ្សាច់ ៤០
ខ.៤.ប. ការដាក់ប្រព័ន្ធបង្ហូរទឹកនៅតាមតំបន់ដែលមានដីឥដ្ឋ ៤០
ខ.៤.ផ. ការដាក់ប្រព័ន្ធបង្ហូរទឹកនៅតាមតំបន់ដែលមានដីខ្សាច់ ៤០
ខ.៤.ព. ការដាក់ប្រព័ន្ធបង្ហូរទឹកនៅតាមតំបន់ដែលមានដីឥដ្ឋ ៤០
ខ.៤.ភ. ការដាក់ប្រព័ន្ធបង្ហូរទឹកនៅតាមតំបន់ដែលមានដីខ្សាច់ ៤០
ខ.៤.ម. ការដាក់ប្រព័ន្ធបង្ហូរទឹកនៅតាមតំបន់ដែលមានដីឥដ្ឋ ៤០
ខ.៤.យ. ការដាក់ប្រព័ន្ធបង្ហូរទឹកនៅតាមតំបន់ដែលមានដីខ្សាច់ ៤០
ខ.៤.រ. ការដាក់ប្រព័ន្ធបង្ហូរទឹកនៅតាមតំបន់ដែលមានដីឥដ្ឋ ៤០
ខ.៤.ល. ការដាក់ប្រព័ន្ធបង្ហូរទឹកនៅតាមតំបន់ដែលមានដីខ្សាច់ ៤០
ខ.៤.វ. ការដាក់ប្រព័ន្ធបង្ហូរទឹកនៅតាមតំបន់ដែលមានដីឥដ្ឋ ៤០
ខ.៤.ស. ការដាក់ប្រព័ន្ធបង្ហូរទឹកនៅតាមតំបន់ដែលមានដីខ្សាច់ ៤០
ខ.៤.ហ. ការដាក់ប្រព័ន្ធបង្ហូរទឹកនៅតាមតំបន់ដែលមានដីឥដ្ឋ ៤០
ខ.៤.ឡ. ការដាក់ប្រព័ន្ធបង្ហូរទឹកនៅតាមតំបន់ដែលមានដីខ្សាច់ ៤០
ខ.៤.អ. ការដាក់ប្រព័ន្ធបង្ហូរទឹកនៅតាមតំបន់ដែលមានដីឥដ្ឋ ៤០
ខ.៤.ឣ. ការដាក់ប្រព័ន្ធបង្ហូរទឹកនៅតាមតំបន់ដែលមានដីខ្សាច់ ៤០
ខ.៤.ឤ. ការដាក់ប្រព័ន្ធបង្ហូរទឹកនៅតាមតំបន់ដែលមានដីឥដ្ឋ ៤០
ខ.៤.ឥ. ការដាក់ប្រព័ន្ធបង្ហូរទឹកនៅតាមតំបន់ដែលមានដីខ្សាច់ ៤០
ខ.៤.ឦ. ការដាក់ប្រព័ន្ធបង្ហូរទឹកនៅតាមតំបន់ដែលមានដីឥដ្ឋ ៤០
ខ.៤.ឧ. ការដាក់ប្រព័ន្ធបង្ហូរទឹកនៅតាមតំបន់ដែលមានដីខ្សាច់ ៤០
ខ.៤.ឩ. ការដាក់ប្រព័ន្ធបង្ហូរទឹកនៅតាមតំបន់ដែលមានដីឥដ្ឋ ៤០
ខ.៤.ឪ. ការដាក់ប្រព័ន្ធបង្ហូរទឹកនៅតាមតំបន់ដែលមានដីខ្សាច់ ៤០
ខ.៤.ឫ. ការដាក់ប្រព័ន្ធបង្ហូរទឹកនៅតាមតំបន់ដែលមានដីឥដ្ឋ ៤០
ខ.៤.ឬ. ការដាក់ប្រព័ន្ធបង្ហូរទឹកនៅតាមតំបន់ដែលមានដីខ្សាច់ ៤០
ខ.៤.ឭ. ការដាក់ប្រព័ន្ធបង្ហូរទឹកនៅតាមតំបន់ដែលមានដីឥដ្ឋ ៤០
ខ.៤.ឮ. ការដាក់ប្រព័ន្ធបង្ហូរទឹកនៅតាមតំបន់ដែលមានដីខ្សាច់ ៤០
ខ.៤.ឯ. ការដាក់ប្រព័ន្ធបង្ហូរទឹកនៅតាមតំបន់ដែលមានដីឥដ្ឋ ៤០
ខ.៤.ឰ. ការដាក់ប្រព័ន្ធបង្ហូរទឹកនៅតាមតំបន់ដែលមានដីខ្សាច់ ៤០
ខ.៤.ឱ. ការដាក់ប្រព័ន្ធបង្ហូរទឹកនៅតាមតំបន់ដែលមានដីឥដ្ឋ ៤០
ខ.៤.ឲ. ការដាក់ប្រព័ន្ធបង្ហូរទឹកនៅតាមតំបន់ដែលមានដីខ្សាច់ ៤០
ខ.៤.ឳ. ការដាក់ប្រព័ន្ធបង្ហូរទឹកនៅតាមតំបន់ដែលមានដីឥដ្ឋ ៤០
ខ.៤.឴. ការដាក់ប្រព័ន្ធបង្ហូរទឹកនៅតាមតំបន់ដែលមានដីខ្សាច់ ៤០
ខ.៤.឵. ការដាក់ប្រព័ន្ធបង្ហូរទឹកនៅតាមតំបន់ដែលមានដីឥដ្ឋ ៤០
ខ.៤.ា. ការដាក់ប្រព័ន្ធបង្ហូរទឹកនៅតាមតំបន់ដែលមានដីខ្សាច់ ៤០
ខ.៤.ិ. ការដាក់ប្រព័ន្ធបង្ហូរទឹកនៅតាមតំបន់ដែលមានដីឥដ្ឋ ៤០
ខ.៤.ី. ការដាក់ប្រព័ន្ធបង្ហូរទឹកនៅតាមតំបន់ដែលមានដីខ្សាច់ ៤០
ខ.៤.ឹ. ការដាក់ប្រព័ន្ធបង្ហូរទឹកនៅតាមតំបន់ដែលមានដីឥដ្ឋ ៤០
ខ.៤.ឺ. ការដាក់ប្រព័ន្ធបង្ហូរទឹកនៅតាមតំបន់ដែលមានដីខ្សាច់ ៤០
ខ.៤.ុ. ការដាក់ប្រព័ន្ធបង្ហូរទឹកនៅតាមតំបន់ដែលមានដីឥដ្ឋ ៤០
ខ.៤.ូ. ការដាក់ប្រព័ន្ធបង្ហូរទឹកនៅតាមតំបន់ដែលមានដីខ្សាច់ ៤០
ខ.៤.ួ. ការដាក់ប្រព័ន្ធបង្ហូរទឹកនៅតាមតំបន់ដែលមានដីឥដ្ឋ ៤០
ខ.៤.ើ. ការដាក់ប្រព័ន្ធបង្ហូរទឹកនៅតាមតំបន់ដែលមានដីខ្សាច់ ៤០
ខ.៤.ឿ. ការដាក់ប្រព័ន្ធបង្ហូរទឹកនៅតាមតំបន់ដែលមានដីឥដ្ឋ ៤០
ខ.៤.ៀ. ការដាក់ប្រព័ន្ធបង្ហូរទឹកនៅតាមតំបន់ដែលមានដីខ្សាច់ ៤០
ខ.៤.េ. ការដាក់ប្រព័ន្ធបង្ហូរទឹកនៅតាមតំបន់ដែលមានដីឥដ្ឋ ៤០
ខ.៤.ែ. ការដាក់ប្រព័ន្ធបង្ហូរទឹកនៅតាមតំបន់ដែលមានដីខ្សាច់ ៤០
ខ.៤.ៃ. ការដាក់ប្រព័ន្ធបង្ហូរទឹកនៅតាមតំបន់ដែលមានដីឥដ្ឋ ៤០
ខ.៤.ោ. ការដាក់ប្រព័ន្ធបង្ហូរទឹកនៅតាមតំបន់ដែលមានដីខ្សាច់ ៤០
ខ.៤.ៅ. ការដាក់ប្រព័ន្ធបង្ហូរទឹកនៅតាមតំបន់ដែលមានដីឥដ្ឋ ៤០
ខ.៤.ំ. ការដាក់ប្រព័ន្ធបង្ហូរទឹកនៅតាមតំបន់ដែលមានដីខ្សាច់ ៤០
ខ.៤.ះ. ការដាក់ប្រព័ន្ធបង្ហូរទឹកនៅតាមតំបន់ដែលមានដីឥដ្ឋ ៤០
ខ.៤.ៈ. ការដាក់ប្រព័ន្ធបង្ហូរទឹកនៅតាមតំបន់ដែលមានដីខ្សាច់ ៤០
ខ.៤.ុំ. ការដាក់ប្រព័ន្ធបង្ហូរទឹកនៅតាមតំបន់ដែលមានដីឥដ្ឋ ៤០
ខ.៤.ូំ. ការដាក់ប្រព័ន្ធបង្ហូរទឹកនៅតាមតំបន់ដែលមានដីខ្សាច់ ៤០
ខ.៤.ួំ. ការដាក់ប្រព័ន្ធបង្ហូរទឹកនៅតាមតំបន់ដែលមានដីឥដ្ឋ ៤០
ខ.៤.ើំ. ការដាក់ប្រព័ន្ធបង្ហូរទឹកនៅតាមតំបន់ដែលមានដីខ្សាច់ ៤០
ខ.៤.ឿំ. ការដាក់ប្រព័ន្ធបង្ហូរទឹកនៅតាមតំបន់ដែលមានដីឥដ្ឋ ៤០
ខ.៤.ៀំ. ការដាក់ប្រព័ន្ធបង្ហូរទឹកនៅតាមតំបន់ដែលមានដីខ្សាច់ ៤០
ខ.៤.េំ. ការដាក់ប្រព័ន្ធបង្ហូរទឹកនៅតាមតំបន់ដែលមានដីឥដ្ឋ ៤០
ខ.៤.ែំ. ការដាក់ប្រព័ន្ធបង្ហូរទឹកនៅតាមតំបន់ដែលមានដីខ្សាច់ ៤០
ខ.៤.ៃំ. ការដាក់ប្រព័ន្ធបង្ហូរទឹកនៅតាមតំបន់ដែលមានដីឥដ្ឋ ៤០
ខ.៤.ោំ. ការដាក់ប្រព័ន្ធបង្ហូរទឹកនៅតាមតំបន់ដែលមានដីខ្សាច់ ៤០
ខ.៤.ៅំ. ការដាក់ប្រព័ន្ធបង្ហូរទឹកនៅតាមតំបន់ដែលមានដីឥដ្ឋ ៤០
ខ.៤.ាំ. ការដាក់ប្រព័ន្ធបង្ហូរទឹកនៅតាមតំបន់ដែលមានដីខ្សាច់ ៤០
ខ.៤.ិំ. ការដាក់ប្រព័ន្ធបង្ហូរទឹកនៅតាមតំបន់ដែលមានដីឥដ្ឋ ៤០
ខ.៤.ីំ. ការដាក់ប្រព័ន្ធបង្ហូរទឹកនៅតាមតំបន់ដែលមានដីខ្សាច់ ៤០
ខ.៤.ឹំ. ការដាក់ប្រព័ន្ធបង្ហូរទឹកនៅតាមតំបន់ដែលមានដីឥដ្ឋ ៤០
ខ.៤.ឺំ

๑



លទ្ធិប្រជាធិបតេយ្យ







គោលបំណង

ដើម្បីឱ្យយុវជនយល់ដឹងអំពីគោលការណ៍ជាមូលដ្ឋាននៃលទ្ធិប្រជាធិបតេយ្យ និង
ទិដ្ឋភាពសំខាន់ៗនៃរបបប្រជាធិបតេយ្យបែបសភានៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

១. លំនាំដើម

របបប្រជាធិបតេយ្យគឺជាទំរង់នៃរដ្ឋាភិបាល ដែលប្រជាពលរដ្ឋជាម្ចាស់អំណាច។ ប្រជាពលរដ្ឋធ្វើសេចក្តីសំរេចចិត្តសំរាប់រដ្ឋាភិបាលរបស់ពួកគេ។ ប្រជាធិបតេយ្យតំណាង ត្រូវបានអនុវត្តនៅក្នុងប្រទេសជាច្រើន។ ក្នុងប្រជាធិបតេយ្យតំណាង ពលរដ្ឋបោះឆ្នោតជ្រើសតាំងតំណាង ដែលតំណាងទាំងនោះជាអ្នកធ្វើសេចក្តីសំរេចចិត្តប្រកបដោយភាពច្បាស់លាស់ និងចាំបាច់សំរាប់អោយរដ្ឋាភិបាលមួយធ្វើការអនុវត្តប្រកបដោយប្រសិទ្ធភាពខ្ពស់បំផុត។

ព្រះរាជាណាចក្រកម្ពុជាអនុវត្តលទ្ធិប្រជាធិបតេយ្យតំណាងជាឧទាហរណ៍ គឺការបោះឆ្នោតជ្រើសតាំងសមាជិករដ្ឋសភា ឬហៅថាតំណាងរាស្ត្រ។ ប្រជាពលរដ្ឋកម្ពុជាជ្រើសតាំងសមាជិកសភា ដើម្បីធ្វើសេចក្តីសំរេចចិត្តជំនួសពួកគាត់។ យើងត្រូវឱ្យសមាជិកសភាទាំងនោះមានការទទួលខុសត្រូវ ប្រសិនបើយើងយល់ថាពួកគាត់ជាតំណាងរបស់យើងទាំងអស់គ្នា ពីព្រោះយើងជាអ្នកបោះឆ្នោតជ្រើសតាំងគាត់។ នៅក្នុងរបបប្រជាធិបតេយ្យអ្នកតំណាងត្រូវទទួលខុសត្រូវចំពោះប្រជាពលរដ្ឋនៅក្នុងមណ្ឌលរបស់ខ្លួន។ ក្នុងអំឡុងពេលបោះឆ្នោត ពលរដ្ឋនៅក្នុងមណ្ឌលនីមួយៗ អាចសំដែងការគាំទ្រ ឬ មិនគាំទ្រតំណាងរបស់ខ្លួនតាមរយៈការបោះឆ្នោតឱ្យ ឬ មិនបោះឱ្យ។

នៅក្នុងពិភពលោក មានទំរង់ជាច្រើននៃរបបប្រជាធិបតេយ្យ។ សហរដ្ឋអាមេរិកប្រកាន់យករបបប្រជាធិបតេយ្យបែបប្រធានាធិបតី។ ប្រទេសឥណ្ឌា អង់គ្លេស អូស្ត្រាលី និង ជប៉ុន ប្រកាន់យករបបប្រជាធិបតេយ្យបែបសភា។ ព្រះរាជាណាកម្ពុជា និង ថៃ ប្រកាន់យករបបប្រជាធិបតេយ្យបែបសភា ដែលមានព្រះមហាក្សត្រជាប្រមុខរដ្ឋ។



២. របបប្រជាធិបតេយ្យបែបសភា នៅព្រះរាជាណាចក្រកម្ពុជា

របបប្រជាធិបតេយ្យបែបសភានៅក្នុងព្រះរាជាណាចក្រកម្ពុជាដូចក្នុងប្រទេសដទៃទៀតដែរ ប្រជាពលរដ្ឋបោះឆ្នោតជ្រើសតាំងតំណាងនៃអង្គការនីតិបញ្ញត្តិ ដែលហៅថារដ្ឋសភា។ បន្ទាប់មកសមាជិកសភាជ្រើសរើសមនុស្សម្នាក់ ដើម្បីដឹកនាំអង្គការនីតិប្រតិបត្តិ។ ប្រព័ន្ធបែបសភានេះ ត្រូវបានអនុវត្តក្នុងប្រទេសជាច្រើនក្នុងទ្វីបអឺរ៉ុប ទ្វីបអាហ្វ្រិក និង ទ្វីបអាស៊ី ដូចជាឥណ្ឌា ជប៉ុន និង ថៃ ជាដើម។

២.១. លក្ខណៈនៃរបបប្រជាធិបតេយ្យបែបសភា នៅព្រះរាជាណាចក្រកម្ពុជា

បន្ទាប់ពីការបោះឆ្នោតឆ្នាំ ១៩៩៣ ព្រះរាជាណាចក្រកម្ពុជាបានអនុម័តនូវរដ្ឋធម្មនុញ្ញរបស់ខ្លួន ដែលប្រកាន់យកការដឹកនាំប្រទេសតាមបែបប្រជាធិបតេយ្យសេរីពហុបក្ស ការគោរពសិទ្ធិមនុស្ស និង នីតិរដ្ឋ។ ព្រះរាជាណាចក្រកម្ពុជាប្រកាន់យករបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ ដែលព្រះមហាក្សត្រទ្រង់ត្រងរាជសម្បត្តិ ប៉ុន្តែទ្រង់មិនកាន់អំណាច។

ដូចរបបប្រជាធិបតេយ្យបែបសភាដទៃទៀតដែរ ប្រជាធិបតេយ្យបែបសភាក្នុងព្រះរាជាណាចក្រកម្ពុជា អាចត្រូវបានកត់សំគាល់តាមរយៈលក្ខណៈមួយចំនួនដូចជា :

- ការបោះឆ្នោតដោយសេរី និង យុត្តិធម៌ និងប្រព្រឹត្តទៅយ៉ាងទៀងទាត់។
- ប្រព័ន្ធពហុបក្ស (មានគណបក្សនយោបាយច្រើន)។
- អ្នកបោះឆ្នោត បោះឆ្នោតជ្រើសតាំងសមាជិកសភា ដើម្បីតំណាងអោយពួកគេនៅក្នុងសភា រួចហើយសមាជិកសភាជ្រើសរើសប្រមុខរាជរដ្ឋាភិបាល និង គណៈរដ្ឋមន្ត្រីទាំងមូល។
- អំណាចនីតិប្រតិបត្តិស្ថិតនៅលើនាយករដ្ឋមន្ត្រី ដែលជាប្រមុខរដ្ឋាភិបាល។ បេក្ខជនមកពីគណបក្ស ដែលមានសម្លេងភាគច្រើនក្លាយជានាយករដ្ឋមន្ត្រី ហើយមានសិទ្ធិរៀបចំគណៈរដ្ឋមន្ត្រី ដើម្បីដាក់ជូនរដ្ឋសភាបោះឆ្នោតផ្តល់សេចក្តីទុកចិត្ត ហើយប្រសិនបើពុំមានគណបក្សណាមួយទទួលបានសម្លេងភាគច្រើនដាច់ខាតទេនោះ គណបក្សដែលជាប់ឆ្នោតត្រូវធ្វើការចរចាគ្នា ដើម្បីបង្កើតរដ្ឋាភិបាលចំរុះមួយ។
- រដ្ឋសភាផ្តល់ការគាំទ្រដល់អង្គការនីតិប្រតិបត្តិតាមរយៈសមាជិករបស់ខ្លួន ហើយសភាក៏អាចដកការគាំទ្ររបស់ខ្លួនពីរដ្ឋាភិបាលគ្រប់ពេលវេលាដែរ។

- គណបក្សជំទាស់មានសិទ្ធិ និង ករណីយកិច្ច ដើម្បីជំទាស់ ឬ រិះគន់ និង ធ្វើឱ្យគណបក្សកាន់អំណាចទទួលខុសត្រូវ គ្រប់ពេលវេលា។

- ប្រព័ន្ធបែបសភានៃព្រះរាជាណាចក្រកម្ពុជា ត្រូវតែពឹង ផ្អែកយ៉ាងច្រើនទៅលើថាមពលនយោបាយផ្ទៃក្នុងរបស់ សភា ដើម្បីឱ្យមានតុល្យភាពនៃអំណាចរបស់រដ្ឋាភិបាល ទាំងមូល។

- រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា អាចធ្វើសេចក្តី ស្នើច្បាប់បាន។

- ព្រះមហាក្សត្រដែលជាប្រមុខរដ្ឋ គឺជានិមិត្តរូបនៃការ បង្រួបបង្រួម និង ឯកភាពជាតិ។ ព្រះមហាក្សត្រ ទ្រង់ពុំ មានអំណាចនយោបាយធំដុំឡើយ។

- **ប្រជាធិបតេយ្យសេរី**: ពាក្យ ប្រជាធិបតេយ្យសេរី មានចែង នៅក្នុងមាត្រា ១ នៃរដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រ កម្ពុជា ដោយផ្អែកទៅលើកិច្ចព្រមព្រៀងសន្តិភាពទីក្រុង ប៉ារីស ឆ្នាំ ១៩៩១។ កិច្ចព្រមព្រៀងនេះ បានកំនត់ឱ្យមាន ការបោះឆ្នោតឆ្នាំ ១៩៩៣ និង ការបង្កើតរដ្ឋធម្មនុញ្ញ ដែល ត្រូវបានអនុម័តនៅពេលក្រោយមក។ ប្រជាធិបតេយ្យ សេរីនៃព្រះរាជាណាចក្រកម្ពុជា មានន័យថា ជាការធានា ថារដ្ឋាភិបាលគឺជាតំណាងយ៉ាងពិតប្រាកដរបស់ពលរដ្ឋ ហើយអាណត្តិនៃសមាជិកអង្គការនីតិបញ្ញត្តិ និង នីតិ-ប្រតិបត្តិត្រូវបានកំនត់ ដោយសារតែពួកគេត្រូវជ្រើសតាំង ឡើងវិញ ឬ ត្រូវជំនួសតាមពេលវេលាឡើងទាត់។



២.២. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

រដ្ឋធម្មនុញ្ញគឺជាកំរងច្បាប់ និងសិទ្ធិជាមូលដ្ឋាន ដែលបង្កើត បានជាមូលដ្ឋានគ្រឹះនៃរដ្ឋាភិបាលមួយ។ ខាងក្រោមនេះ គឺជា ទិដ្ឋភាពសំខាន់ៗមួយចំនួន ដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញនៃ ព្រះរាជាណាចក្រកម្ពុជា :

- **មូលដ្ឋានគ្រឹះនៃច្បាប់** : ដូចជារដ្ឋធម្មនុញ្ញនៃប្រទេស ដែល ប្រកាន់របបប្រជាធិបតេយ្យដទៃទៀតដែរ រដ្ឋធម្មនុញ្ញនៃ ព្រះរាជាណាចក្រកម្ពុជា គឺជាច្បាប់កំពូលរបស់ប្រទេស ដែលបង្កើតបានជាមូលដ្ឋានគ្រឹះសំរាប់ច្បាប់ទាំងឡាយ របស់ប្រទេស។ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានតាក់តែងឡើងដោយចែកចេញជា បុព្វកថា និង ជំពូកចំនួន ១៦ ដែលមាន ១៥៨ មាត្រា។ រដ្ឋធម្មនុញ្ញ បានធានាចំពោះរាល់ពលរដ្ឋកម្ពុជាទាំងអស់នូវសិទ្ធិ និង សេរីភាពជាមូលដ្ឋានរបស់ខ្លួន។

- **រាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ** : យោងតាមរដ្ឋធម្មនុញ្ញ ប្រទេសកម្ពុជា គឺជាព្រះរាជាណាចក្រ ដែលមានព្រះ-មហាក្សត្រទ្រង់គ្រងរាជ្យ ប៉ុន្តែមិនកាន់អំណាច។ តួនាទី និងអំណាចរបស់ព្រះមហាក្សត្រ ត្រូវបានចែងយ៉ាងច្បាស់ នៅក្នុងរដ្ឋធម្មនុញ្ញ។ ដូចនេះ វត្តមាននៃស្ថាប័នព្រះ-មហាក្សត្រ និង រដ្ឋធម្មនុញ្ញ បង្កើតបានជារបបរាជានិយម អាស្រ័យរដ្ឋធម្មនុញ្ញនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ នេះមានន័យថា អំណាចនៃស្ថាប័នព្រះមហាក្សត្រត្រូវបាន កំនត់ទៅតាមអ្វីដែលត្រូវអនុញ្ញាតនៅក្រោមបទបញ្ញត្តិ នៃរដ្ឋធម្មនុញ្ញ។

- **ឯកិរាជ្យ** : នៅក្នុងរបបប្រជាធិបតេយ្យ ពលរដ្ឋត្រូវតែគោរព ច្បាប់ និង មានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់។ ចំនុចនេះ ក៏ត្រូវបានចែងផងដែរ នៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះ-រាជាណាចក្រកម្ពុជា ដែលបានចែងថា ប្រជាពលរដ្ឋខ្មែរ គ្រប់រូបមានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់។

- **សេរីភាពនៃទីផ្សារ** : រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បានអនុម័តយកប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ ដែលអនុញ្ញាតឱ្យ ប្រជាពលរដ្ឋមានទ្រព្យសម្បត្តិ កម្មសិទ្ធិផ្ទាល់ខ្លួន និង ប្រកបរបរអាជីវកម្ម និង លក់ផលិតផល ដែលខ្លួនផលិតបាន ទៅលើទីផ្សារ។

- **ការបោះឆ្នោតដោយសេរី និង យុត្តិធម៌** : យោងតាមរដ្ឋ ធម្មនុញ្ញ ពលរដ្ឋកម្ពុជាជ្រើសតាំងតំណាង ដើម្បីធ្វើជា តំណាងឱ្យពួកគេនៅក្នុងសភា តាមរយៈការបោះឆ្នោត មួយប្រកបដោយលក្ខណៈសេរី ត្រឹមត្រូវ យុត្តិធម៌ និង ទៀងទាត់។

- **ការបែងចែកអំណាច** : រដ្ឋធម្មនុញ្ញ កំនត់ឱ្យមានរដ្ឋាភិបាល មួយដែលមានតុល្យភាព ដោយបែងចែកអំណាចគ្រប់-គ្រងរដ្ឋជាបី គឺ នីតិបញ្ញត្តិ នីតិប្រតិបត្តិ និង តុលាការ។ សាខានីតិប្រតិបត្តិ ជាអ្នកពង្រឹង និង អនុវត្តច្បាប់ សាខា នីតិបញ្ញត្តិ ជាអ្នកធ្វើច្បាប់ និង សាខាតុលាការ ជាអ្នក ពន្យល់ និង វិនិច្ឆ័យការអនុវត្តច្បាប់។ សាខានីតិប្រតិបត្តិ គឺតំណាងដោយរាជរដ្ឋាភិបាល សាខានីតិបញ្ញត្តិ គឺតំណាង ដោយរដ្ឋសភា និង ព្រឹទ្ធសភា សាខាតុលាការ គឺតំណាង ដោយស្ថាប័នតុលាការ ឬ សាលាជំរះក្តី។

- **ការគោរពសិទ្ធិមនុស្ស** : រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រ កម្ពុជាទទួលស្គាល់ និង គោរពសិទ្ធិមនុស្ស ដែលបានចែង នៅក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ សេចក្តីថ្លែងការណ៍ ជាសកលស្តីពីសិទ្ធិមនុស្ស និង កតិកាសញ្ញា ព្រមទាំង អនុសញ្ញាផ្សេងៗ ដែលទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិ ស្ត្រី និង សិទ្ធិកុមារ។

- **ករណីយកិច្ចរបស់ពលរដ្ឋខ្មែរ** : ករណីយកិច្ច និង ការទទួល ខុសត្រូវរបស់ពលរដ្ឋខ្មែរ ត្រូវបានទទួលស្គាល់យ៉ាង ច្បាស់លាស់ដោយរដ្ឋធម្មនុញ្ញ។ ឧទាហរណ៍ ពលរដ្ឋខ្មែរ មានករណីយកិច្ចនៅក្នុងការបោះឆ្នោត ឈរឈ្មោះជា បេក្ខជន និង គោរពរដ្ឋធម្មនុញ្ញ និង ច្បាប់។

(សូមមើលជំពូកទី III ក្នុងរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា)

២.៣. រចនាសម្ព័ន្ធនៃការគ្រប់គ្រងរដ្ឋ របស់ព្រះរាជាណាចក្រកម្ពុជា

ស្ថាប័នព្រះមហាក្សត្រ

យោងតាមរដ្ឋធម្មនុញ្ញ ព្រះរាជាណាចក្រកម្ពុជាប្រកាន់របបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ ក្នុងនោះព្រះមហាក្សត្រគឺជានិមិត្តរូបនៃឯកភាព និង និរន្តរភាពជាតិ ហើយទ្រង់គ្រងរាជ្យប៉ុន្តែមិនកាន់អំណាច។ ព្រះមហាក្សត្រ គឺជាប្រមុខរដ្ឋអស់មួយជីវិត។ សេចក្តីព្រាងច្បាប់ដែលបានអនុម័តដោយសភា និងត្រួតពិនិត្យចប់សព្វគ្រប់ដោយព្រឹទ្ធសភា អាចក្លាយជាច្បាប់បានបន្ទាប់ពីការប្រកាសអោយប្រើដោយព្រះមហាក្សត្រ។ ក្នុងព្រះបរមនាមជាប្រមុខរដ្ឋ ព្រះមហាក្សត្រត្រូវបានផ្តល់អំណាចខ្លះៗដោយរដ្ឋធម្មនុញ្ញក្នុងការតែងតាំង និង ការផ្តល់សច្ចាប័ន។ អំណាចទាំងនោះរួមមានការតែងតាំងនាយករដ្ឋមន្ត្រី គណៈ-រដ្ឋមន្ត្រី ឯកអគ្គរាជទូត មន្ត្រីជាន់ខ្ពស់យោធា និង ស៊ីវិល និងឡាយព្រះហស្តលេខាលើសន្ធិសញ្ញា និង អនុសញ្ញាអន្តរជាតិនានា បន្ទាប់ពីការអនុម័តយល់ព្រមនឹងអនុសាសន៍របស់រដ្ឋសភា។ ព្រះមហាក្សត្រ ក៏មានព្រះរាជសិទ្ធិក្នុងការផ្តល់ការបន្ធូរបន្ថយ និងការលើកលែងទោស និង ទ្រង់ជាមេបញ្ជាការកំពូលនៃកងយោធពលខេមរភូមិន្ទផងដែរ។ ក្រៅពីអំណាចទាំងនេះព្រះមហាក្សត្រមានតួនាទីដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ ដូចជា :

- ជាអ្នកធានានូវឯករាជ្យជាតិ អធិបតេយ្យ និង បូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា។
- ជាអ្នកធានាការគោរពសិទ្ធិ និង សេរីភាពរបស់ប្រជា-ពលរដ្ឋ។
- ជាអ្នកធានាការគោរពសន្ធិសញ្ញាអន្តរជាតិ។
- ទ្រង់មានតួនាទីខ្ពង់ខ្ពស់ជាអាជ្ញាកណ្តាល ដើម្បីធានាការប្រព្រឹត្តទៅនៃអំណាចសាធារណៈអោយមានភាពឡើងទាត់។



សាខានីតិបញ្ញត្តិ

សាខានីតិបញ្ញត្តិ រួមមាន រដ្ឋសភា និង ព្រឹទ្ធសភា។ រដ្ឋសភាមានសមាជិក ១២៣រូប តំណាងឱ្យប្រជាពលរដ្ឋ ២៤ខេត្ត/ក្រុង ដែលត្រូវបានជ្រើសតាំងដោយការបោះឆ្នោតពីប្រជាពលរដ្ឋដោយផ្ទាល់នៅក្នុងមណ្ឌលរបស់ខ្លួន សំរាប់បំរើការងារក្នុងអាណត្តិ ៥ឆ្នាំ។ សមាជិកនៃរដ្ឋសភា ត្រូវបានជ្រើសតាំងតាមរយៈការបោះឆ្នោតតាមប្រព័ន្ធសមាមាត្រដោយផ្អែកលើចំនួនប្រជាពលរដ្ឋ។ អំណាចសំខាន់ៗរបស់រដ្ឋសភា គឺជាតំណាងរបស់ប្រជាពលរដ្ឋ បង្កើតច្បាប់ ផ្តល់សច្ចាប័នចំពោះសន្ធិសញ្ញា និង កិច្ចព្រមព្រៀងអន្តរជាតិផ្សេងៗ អនុម័តថវិកាជាតិ និងត្រួតពិនិត្យសកម្មភាពផ្សេងៗរបស់រដ្ឋាភិបាល។ ចំណែកឯសមាជិកព្រឹទ្ធសភាវិញ មានចំនួនមិនលើសពីពាក់កណ្តាលនៃចំនួនសមាជិករដ្ឋសភាឡើយ ហើយកាន់តំណែងក្នុងអាណត្តិ ៦ឆ្នាំ។ រដ្ឋធម្មនុញ្ញមិនបានផ្តល់អំណាចដល់ព្រឹទ្ធសភាច្រើនទេក្រៅពីអំណាច ឬ តួនាទីផ្តល់យោបល់ ដើម្បីលើកអនុសាសន៍ពាក់ព័ន្ធទៅនឹងច្បាប់ដែលបានអនុម័តដោយរដ្ឋសភា។ ទាំងរដ្ឋសភា និង ព្រឹទ្ធសភា មានរចនាសម្ព័ន្ធដូចគ្នា ដែលក្នុងនោះត្រូវបានដឹកនាំដោយ ប្រធានមួយរូប អនុប្រធានពីររូប និងប្រធានគណៈកម្មការទាំង ៩ របស់ខ្លួន ដែលហៅថា ជាគណៈកម្មាធិការអចិន្ត្រៃយ៍ ដែលទទួលខុសត្រូវក្នុងការចាត់ចែងកិច្ចការប្រចាំថ្ងៃរបស់រដ្ឋសភា និង ព្រឹទ្ធសភា។



សាខានីតិប្រតិបត្តិ

សាខានីតិប្រតិបត្តិ គឺស្ថិតនៅលើគណៈរដ្ឋមន្ត្រី ឬរាជ-រដ្ឋាភិបាលកម្ពុជា ដែលរួមមានសមាសភាព ដូចជានាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និង រដ្ឋលេខាធិការ។ សមាជិកនៃរាជរដ្ឋាភិបាលទាំងអស់ ត្រូវទទួលខុសត្រូវរួមគ្នាចំពោះរដ្ឋសភា និង រាល់សមាជិកម្នាក់ៗនៃរាជរដ្ឋាភិបាលត្រូវទទួលខុសត្រូវដោយផ្ទាល់ជាមួយនាយករដ្ឋមន្ត្រី និង សភាចំពោះសកម្មភាពរបស់ខ្លួន។ សមាជិកគណៈរដ្ឋមន្ត្រី ក៏អាចជាសមាជិកនៃរដ្ឋសភាផងដែរ។



សាខានីតិប្រតិបត្តិអាចអនុវត្ត និង ប្រតិបត្តិច្បាប់ ដែលបានអនុម័តដោយរដ្ឋសភា អនុវត្តសកម្មភាពនានារបស់រដ្ឋាភិបាល និង បង្កើតគោលនយោបាយរបស់រដ្ឋាភិបាល។ សាខានីតិប្រតិបត្តិក៏អាចស្នើច្បាប់ ដើម្បីដាក់អោយសាខានីតិបញ្ញត្តិ ធ្វើការពិចារណា និង ស្នើគំរោងថវិកាប្រចាំឆ្នាំសំរាប់រាជរដ្ឋាភិបាលផងដែរ។ ជាងនេះទៅទៀត សាខានីតិប្រតិបត្តិ ត្រូវតែមានការទទួលខុសត្រូវក្នុងការធានាអោយមានសន្តិភាព និង ស្ថេរភាពរបស់សង្គមជាតិ ការពារ និង លើកស្ទួយសិទ្ធិមនុស្ស លើកស្ទួយកំរិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ការពារអធិបតេយ្យភាព និង បូរណភាពទឹកដី។ តែទោះជាយ៉ាងណាក៏ដោយ អាចមានការផ្ទេរអំណាចទៅក្រសួង ឬ អាជ្ញាធររបស់រដ្ឋាភិបាល ដើម្បីបង្កើតច្បាប់ ឬ បទបញ្ជាផ្សេងៗ ដូចជា អនុក្រឹត្យ សេចក្តីប្រកាស សេចក្តីសំរេច សារាចរណែនាំ ប៉ុន្តែការអនុវត្តនេះត្រូវតែអនុលោមយ៉ាងម៉ឺងម៉ាត់ទៅតាមច្បាប់ដែលបានអនុម័តដោយរដ្ឋសភា។

ក្នុងន័យរដ្ឋបាល រដ្ឋធម្មនុញ្ញបានបញ្ជាក់ថា ប្រទេសកម្ពុជា ត្រូវបានបែងចែកជា ខេត្ត/ក្រុង ស្រុក/ខ័ណ្ឌ និង ឃុំ/សង្កាត់ ដែលត្រូវបានគេហៅថា រដ្ឋាភិបាល ឬ អាជ្ញាធរមូលដ្ឋាន និង ត្រូវគ្រប់គ្រងតាមលក្ខខណ្ឌ ដែលមានចែងក្នុងច្បាប់រដ្ឋបាលមួយ។





៣. ភាពខុសគ្នារវាងការគ្រប់គ្រងបែបផ្តាច់ការ និង ការគ្រប់គ្រងបែបប្រជាធិបតេយ្យ



នៅក្នុងលទ្ធិផ្តាច់ការ បុគ្គលម្នាក់ ឬ ក្រុមមនុស្សមួយក្រុមតូចជាអ្នកកាន់អំណាច។ សម្តីរបស់ជនផ្តាច់ការ គឺជាច្បាប់។ ជនផ្តាច់ការ ឬ ក្រុមអ្នកដឹកនាំទាំងនោះ មិនដែលទទួលខុសត្រូវចំពោះឆន្ទៈរបស់ប្រជាពលរដ្ឋឡើយ។ របបណាហ្ស៊ីអាល្លឺម៉ង់ ស្ថិតនៅក្រោមជនផ្តាច់ការ **ហ៊ីត្លែរ** ប្រទេសកម្ពុជា ស្ថិតនៅក្រោមជនផ្តាច់ការ **ប៉ុល ពត** ប្រទេសភូមា ស្ថិតនៅក្រោមជនផ្តាច់ការ **ថាន់ស្វេ** ប្រទេសអ៊ូហ្គង់ដា ស្ថិតនៅក្រោមជនផ្តាច់ការ **អេឌី អាមីន** ទាំងអស់នេះ គឺសុទ្ធតែជាគំរូនៃការគ្រប់គ្រងតាមបែបផ្តាច់ការ។

រដ្ឋាភិបាលរាជានិយម និងសមស្តនិយមត្រួតត្រាដោយយោធា ឬ ក្រុមជនស៊ីវិលមួយក្តាប់តូច (ឧទាហរណ៍ : គណបក្សកុម្មុយនិស្តរបស់អតីតសហភាពសូវៀត)។ របបរាជានិយមក៏អាចជារបបផ្តាច់ការដែរ នៅពេលណាដែលព្រះរាជា ឬ ព្រះរាជិនី ឬ សមាជិកនៃក្រុមព្រះញាតិវង្សានុវង្សស្នងតំណែង និង ប្រើអំណាចគ្មានព្រំដែនកំណត់។

ជួនកាលរបបផ្តាច់ការហាក់ដូចជាមានប្រជាធិបតេយ្យដែរ និង ដូចជាត្រួតត្រាដោយពលរដ្ឋ។ ពលរដ្ឋបោះឆ្នោតក្នុងការបោះឆ្នោតតាមគេនិយម ប៉ុន្តែការបោះឆ្នោតនេះ ត្រូវបានត្រួតត្រាយ៉ាងតឹងរឹង ហើយបេក្ខជនមកពីគណបក្សនយោបាយតែមួយគឺគណបក្សរបស់មេផ្តាច់ការ។ អង្គការនីតិបញ្ញត្តិ អាចមានប៉ុន្តែតាមធម្មតាអង្គការនេះ គ្រាន់តែចាំអនុម័តនយោបាយជនផ្តាច់ការតែប៉ុណ្ណោះ ដែលត្រូវបានគេហៅថា សភាប្រថាប់ត្រា។ ជនផ្តាច់ការជាច្រើន មិនបានជ្រើសរើសដោយបោះឆ្នោតទេ ប៉ុន្តែពួកនេះទទួលអំណាចដោយប្រើកម្លាំង។ ជនផ្តាច់ការខ្លះជាមេដឹកនាំយោធា ហើយជនផ្តាច់ការដទៃទៀត ប្រើកម្លាំងយោធាដើម្បីជួយសំរេចក្នុងការត្រួតត្រារដ្ឋាភិបាល។

ចូរអ្នកពិនិត្យមើលតារាងប្រៀបធៀបសង្ខេបខាងក្រោមនេះ ថាតើរបបត្រួតត្រាណាមួយដែលអ្នកយល់ថាល្អ?

ប្រភេទ \ របប	របបផ្តាច់ការ	របបប្រជាធិបតេយ្យ
អំណាច	នៅលើអ្នកដឹកនាំ/បក្សពួក	នៅលើប្រជាពលរដ្ឋ
ច្បាប់	ចេញពីមាត់អ្នកដឹកនាំ	ចេញពីប្រជាពលរដ្ឋ តាមរយៈតំណាង
ផលប្រយោជន៍	បានទៅអ្នកដឹកនាំ/បក្សពួក	បានទៅប្រជាពលរដ្ឋ

៤. គោលការណ៍សំខាន់ៗ នៃរបបប្រជាធិបតេយ្យ

ពលរដ្ឋនៅទូទាំងពិភពលោក បានកំណត់គោលការណ៍ជាមូលដ្ឋានដែលត្រូវតែមានអត្ថិភាព ដើម្បីឱ្យមានរដ្ឋាភិបាលប្រជាធិបតេយ្យ។ គោលការណ៍ទាំងនេះ ជារឿយៗក្លាយជាផ្នែកមួយនៃរដ្ឋធម្មនុញ្ញនៅក្នុងប្រទេសប្រជាធិបតេយ្យ។ ក្នុងនាមជាឃុវជន អ្នកត្រូវតែស្វែងយល់អោយបានច្បាស់ពីលក្ខណៈនៃរបបប្រជាធិបតេយ្យ ដើម្បីអោយអ្នកក្លាយជាពលរដ្ឋល្អម្នាក់ក្នុងសង្គម។

ចូរពិនិត្យមើលគោលការណ៍ទាំងឡាយនៃរបបប្រជាធិបតេយ្យ ដូចខាងក្រោមនេះ ហើយសាកល្បងប្រៀបធៀបពីការអនុវត្តជាក់ស្តែងនៅក្នុងសង្គមខ្មែរបច្ចុប្បន្ន ទៅនឹងគោលការណ៍ទាំងនោះ។

ប្រព័ន្ធពហុបក្ស : ដើម្បីមានប្រព័ន្ធពហុបក្ស ត្រូវមានគណបក្សនយោបាយច្រើនចូលរួមក្នុងការបោះឆ្នោត ហើយគណបក្សទាំងអស់មានឱកាសប្រកួតប្រជែងដូចគ្នា និង ស្មើៗគ្នា។ ប្រព័ន្ធពហុបក្សផ្តល់ឱ្យអ្នកបោះឆ្នោតជ្រើសរើសបេក្ខជន/គណបក្សនយោបាយនៅពេលបោះឆ្នោត។ ជាប្រវត្តិសាស្ត្រនៅពេលដែលប្រទេសមួយមានតែគណបក្សមួយ លទ្ធផលគឺផ្តាច់ការ។ ប្រព័ន្ធពហុបក្សផ្តល់ឱ្យមានការជំទាស់ទៅនឹងគណបក្សដែលឈ្នះឆ្នោត។ ធ្វើដូចនេះ អាចជួយផ្តល់នូវទស្សនៈផ្សេងៗទៅលើបញ្ហានានាដល់រដ្ឋាភិបាល។



ការបោះឆ្នោតដោយសេរី ត្រឹមត្រូវ និង ទៀងទាត់ : វិធីមួយដែលពលរដ្ឋរបស់ប្រទេសសំដែងសុច្ឆន្ទៈរបស់គេ គឺដោយជ្រើសតាំងមន្ត្រីឱ្យតំណាងពួកគេនៅក្នុងរដ្ឋាភិបាល។ របបប្រជាធិបតេយ្យតម្រូវឱ្យមន្ត្រីទាំងនោះ ត្រូវបានជ្រើសតាំងឡើងតាមរយៈការបោះឆ្នោត ហើយត្រូវបានដកចេញពីតំណែងដោយសន្តិវិធី និងក្នុងលក្ខណៈសេរី និង ត្រឹមត្រូវ។ ការបំភិតបំភ័យ អំពើពុករលួយ និង ការគំរាមកំហែងប្រជាពលរដ្ឋក្នុងអំឡុងពេលមុន និង ក្រោយពេលបោះឆ្នោត គឺប្រឆាំងទៅនឹងគោលការណ៍លទ្ធិប្រជាធិបតេយ្យ។

នៅក្នុងរបបប្រជាធិបតេយ្យ ការបោះឆ្នោតត្រូវធ្វើឡើងជាទៀងទាត់។ នៅសហរដ្ឋអាមេរិក ប្រធានាធិបតី ត្រូវបានជ្រើសតាំងឡើងវេរាល់ ៤ ឆ្នាំម្តង សមាជិកសភារាល់ ២ ឆ្នាំម្តង និង សមាជិកព្រឹទ្ធសភារាល់ ៦ ឆ្នាំម្តង។ រីឯក្នុងព្រះរាជាណាចក្រកម្ពុជាវិញ សមាជិកសភា ត្រូវបានជ្រើសតាំងឡើងរាល់ ៥ ឆ្នាំ ម្តង។

ដើម្បីអោយមានការបោះឆ្នោតដោយសេរី និងត្រឹមត្រូវកើតឡើង ពលរដ្ឋគ្រប់វ័យទាំងអស់ត្រូវមានសិទ្ធិឈរឈ្មោះដើម្បីប្រកួតប្រជែងយកតំណែងនៅក្នុងរដ្ឋាភិបាល។ លើសពីនេះទៅទៀត មិនត្រូវបង្កើតឱ្យមានឧបសគ្គពិបាកកើតមានឡើងដល់ប្រជាពលរដ្ឋក្នុងការបោះឆ្នោតឡើយ។

ការទទួលស្គាល់លទ្ធផលបោះឆ្នោត : ក្នុងការបោះឆ្នោតបែបប្រជាធិបតេយ្យ ត្រូវមានអ្នកឈ្នះ និង អ្នកចាញ់។ ជារឿយៗអ្នកចាញ់នៅក្នុងការបោះឆ្នោតជឿជាក់យ៉ាងមុតមាំថា គណបក្ស និង បេក្ខជនរបស់ខ្លួនមានលក្ខណៈដ៏ល្អប្រពៃបំផុត ហើយពួកគេអាចបដិសេធមិនទទួលយកលទ្ធផលនៃការបោះឆ្នោត។ ការធ្វើបែបនេះ គឺប្រឆាំងទៅនឹងគោលការណ៍ប្រជាធិបតេយ្យ។ ផលវិបាកនៃការមិនទទួលយកលទ្ធផលបោះឆ្នោត អាចធ្វើឱ្យរដ្ឋាភិបាលគ្មានប្រសិទ្ធភាព និង មិនអាចធ្វើសេចក្តីសំរេចចិត្តបាន។ លើសពីនេះ វាអាចកើតមានអំពើហិង្សា ដែលមិនមែនជាវិធីដោះស្រាយក្នុងរបបប្រជាធិបតេយ្យទៀតផង។

ការចូលរួមរបស់ប្រជាពលរដ្ឋ : គោលការណ៍មួយក្នុងចំណោមគោលការណ៍ជាមូលដ្ឋានបំផុតនៃរបបប្រជាធិបតេយ្យ គឺការចូលរួមរបស់ប្រជាពលរដ្ឋ នៅក្នុងការគ្រប់គ្រងប្រទេស។ ការចូលរួម គឺជាតួនាទីដ៏សំខាន់របស់ប្រជាពលរដ្ឋនៅក្នុងរបបប្រជាធិបតេយ្យ។ ការចូលរួមនេះ វាមិនត្រឹមតែជាសិទ្ធិរបស់ពួកគេប៉ុណ្ណោះទេ តែវាជាកាតព្វកិច្ចទៀតផង។ ការចូលរួមរបស់ប្រជាពលរដ្ឋ អាចធ្វើឡើងតាមទ្រង់ទ្រាយជាច្រើនរួមមាន ការទៅបោះឆ្នោត ការទទួលបានព័ត៌មាន ការពិភាក្សាបញ្ហា ការចូលរួមក្នុងសហគមន៍ ឬ ការជួបជុំប្រជាពលរដ្ឋ ការក្លាយជាសមាជិកនៃអង្គការស្ម័គ្រចិត្ត ការបង់ពន្ធ និង ការតវ៉ាជាដើម។ ការចូលរួមទាំងនេះ ធ្វើឱ្យពលរដ្ឋមានចំនែកក្នុងការសំរេចចិត្ត និង យល់ច្បាស់ពីការសំរេចចិត្តផងដែរ។

ភាពស្មើគ្នា : របបប្រជាធិបតេយ្យ សង្កត់ធ្ងន់លើគោលការណ៍ដែលពលរដ្ឋទាំងអស់មានសិទ្ធិស្មើគ្នា។ ភាពស្មើគ្នាមានន័យថា បុគ្គលទាំងអស់មានតម្លៃស្មើៗគ្នា និង មិនអាចរើសអើងដោយសារតែពូជសាសន៍ សាសនា ក្រុមជនជាតិភាគតិច ភេទ។ល។ នៅក្នុងរបបប្រជាធិបតេយ្យ បុគ្គល និង ក្រុមផ្សេងៗ នៅតែមានសិទ្ធិរបស់គេឱ្យមានវប្បធម៌ បុគ្គលិកលក្ខណៈ ភាសា និង ជំនឿផ្សេងៗគ្នា។ មនុស្សទាំងអស់ត្រូវប្រព្រឹត្តដោយស្មើៗគ្នា នៅចំពោះមុខច្បាប់។

ការអត់ឱនខាងនយោបាយ : របបប្រជាធិបតេយ្យ មានការអត់ឱនខាងនយោបាយ។ បញ្ហានេះមានន័យថា នៅពេលដែលមតិភាគច្រើនគ្រប់គ្រងនៅក្នុងរបបប្រជាធិបតេយ្យ សិទ្ធិនៃមតិភាគតិច និង គណបក្សជំទាស់ត្រូវបានការពារ។ ពលរដ្ឋត្រូវតែបានការអនុញ្ញាតឱ្យរៀបចំ និង សំដែងចេញនូវមតិ។ ពលរដ្ឋម្នាក់ៗត្រូវមានការអត់ឱនឱ្យគ្នាទៅវិញទៅមកផងដែរ។

តាមធម្មតា របបប្រជាធិបតេយ្យមានពលរដ្ឋមកពីវប្បធម៌ផ្សេងៗគ្នា ពូជសាសន៍ សាសនា និង ក្រុមជនជាតិភាគតិចដែលទស្សនៈខុសប្លែកពីពលរដ្ឋមតិភាគច្រើន។ ភាពផ្សេងៗគ្នា (Diversity) គឺជាតំលៃរបស់របបប្រជាធិបតេយ្យ។ ប្រសិនបើមតិភាគច្រើនបដិសេធ និង បំផ្លាញគណបក្សជំទាស់របស់គេនោះ គឺដូចជាការបំផ្លាញរបបប្រជាធិបតេយ្យដែរ។ ក្នុងរបបប្រជាធិបតេយ្យសិទ្ធិជនជាតិភាគតិច សាសនា និង សម្លេងភាគតិចខាងនយោបាយត្រូវបានការពារដោយច្បាប់។







ការទទួលខុសត្រូវ : ក្នុងរបបប្រជាធិបតេយ្យ មន្ត្រីដែលត្រូវបានតែងតាំង និង ជ្រើសតាំងត្រូវទទួលខុសត្រូវចំពោះមុខប្រជាពលរដ្ឋ នូវរាល់សកម្មភាពរបស់ខ្លួន។ ពោលគឺ ត្រូវធ្វើសេចក្តីសំរេចចិត្ត និង បំពេញភារកិច្ចយោងតាមឆន្ទៈ និង គោលបំណងប្រជាពលរដ្ឋ មិនមែនខ្លួនឯងទេ។ ប្រសិនបើមន្ត្រីទាំងនោះមិនបំពេញការងាររបស់ខ្លួនឱ្យបានត្រឹមត្រូវទេ ប្រជាពលរដ្ឋអាចបោះឆ្នោតជ្រើសតាំងអ្នកផ្សេងទៀត។ ដូចនេះ អ្នកតំណាងត្រូវតែដឹងពីសុខទុក្ខរបស់ប្រជាពលរដ្ឋ ពោលគឺ ត្រូវចុះជាប់ជាមួយពលរដ្ឋ ហើយត្រូវប្រមូលឱ្យខាងតែបាននូវព័ត៌មានស្តីពីការព្រួយបារម្ភរបស់ពលរដ្ឋខ្លួន។

តម្លាភាព : រដ្ឋាភិបាលតម្លាភាព ត្រូវធ្វើការជួបជុំជាសាធារណៈ ចំណាត់ការច្បាប់ និង ឱ្យពលរដ្ឋចូលរួម ហើយឯកសារស្តីអំពីរដ្ឋាភិបាលត្រូវមានជូនដល់ប្រជាពលរដ្ឋ ប្រសិនបើឯកសារនោះមិនមានប៉ះពាល់ដល់ផលប្រយោជន៍សន្តិសុខជាតិនោះទេ។ នៅក្នុងរបបប្រជាធិបតេយ្យ ប្រជាពលរដ្ឋអាចទទួលព័ត៌មានអំពីអ្វី ដែលជាសេចក្តីសំរេចកំពុងធ្វើឡើង ធ្វើដោយអ្នកណា និង មូលហេតុអ្វី?

តម្លាភាព

ការប្តឹងជំទាស់លទ្ធផលបោះឆ្នោត : ការប្តឹងតវ៉ាលទ្ធផលបោះឆ្នោតត្រូវធ្វើឡើងតាមរយៈសារណាជាលាយលក្ខណ៍អក្សរ ដែលត្រូវដាក់ជូនតុលាការ ឬ ទីស្នាក់ការរបស់ចៅក្រមប្រចាំតំបន់ឃុំ/សង្កាត់ ក្នុងរយៈពេលមួយថ្ងៃ គិតចាប់ពីថ្ងៃបិទការបោះឆ្នោត ដោយមានការចុះហត្ថលេខារបស់តំណាងគណបក្សនយោបាយ ឬ បេក្ខជនឯករាជ្យ ដែលបានចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោតនោះ ។ ការប្តឹងតវ៉ាលទ្ធផលបោះឆ្នោតត្រូវមានហេតុផលច្បាស់លាស់ និង ភស្តុតាងគាំទ្រ ដើម្បីឱ្យតុលាការអាចពិនិត្យ និង សម្រេចបានត្រឹមត្រូវ ។ ក្នុងករណីដែលតុលាការទទួលយកបណ្តឹងតវ៉ា តុលាការនឹងកោះហៅភាគីពាក់ព័ន្ធទាំងអស់ឱ្យចូលបង្ហាញភស្តុតាង និង ការពន្យល់ជាលាយលក្ខណ៍អក្សរ ឬ តាមរយៈការសាកសួរដោយផ្ទាល់មាត់ នៅក្នុងសវនាការជាសាធារណៈ ។ តុលាការត្រូវសម្រេចលើបណ្តឹងតវ៉ាក្នុងរយៈពេលមិនលើសពីប្រាំពីរថ្ងៃ គិតចាប់ពីថ្ងៃទទួលបានបណ្តឹង ដើម្បីធានាឱ្យមានដំណោះស្រាយទាន់ពេលវេលា និង ការពារដំណើរការប្រជាធិបតេយ្យ ។

ការសម្រេចរបស់តុលាការ : តុលាការមានសិទ្ធិសម្រេចលើលទ្ធផលមួយចំនួន ឬ លើកលែងទាំងស្រុងនូវលទ្ធផលនៃការបោះឆ្នោតក្នុងតំបន់ឃុំ/សង្កាត់ណាមួយ ប្រសិនបើតុលាការរកឃើញថាមានការរំលោភបំពានយ៉ាងធ្ងន់ធ្ងរ ដែលប៉ះពាល់ដល់លទ្ធផលនៃការបោះឆ្នោត ។ ការសម្រេចរបស់តុលាការត្រូវមានលក្ខណៈជាលាយលក្ខណ៍អក្សរ ហើយត្រូវមានហេតុផលច្បាស់លាស់ និង ផ្អែកលើភស្តុតាងដែលបានដាក់ជូន ។ សេចក្តីសម្រេចនេះត្រូវបានជូនដំណឹងដល់គណបក្សនយោបាយ និង បេក្ខជនឯករាជ្យដែលពាក់ព័ន្ធ ក្នុងរយៈពេលមិនលើសពីបីថ្ងៃ គិតចាប់ពីថ្ងៃសម្រេច ។ ការសម្រេចរបស់តុលាការជាចុងក្រោយ មិនអាចប្តឹងតវ៉ាបន្តទៀតបានឡើយ ដើម្បីធានាឱ្យមានភាពច្បាស់លាស់ និង ស្ថិរភាពនយោបាយ ។



ការប្តឹងជំទាស់លទ្ធផលបោះឆ្នោត : ការប្តឹងតវ៉ាលទ្ធផលបោះឆ្នោតត្រូវធ្វើឡើងតាមរយៈសារណាជាលាយលក្ខណ៍អក្សរ ដែលត្រូវដាក់ជូនតុលាការ ឬ ទីស្នាក់ការរបស់ចៅក្រមប្រចាំតំបន់ឃុំ/សង្កាត់ ក្នុងរយៈពេលមួយថ្ងៃ គិតចាប់ពីថ្ងៃបិទការបោះឆ្នោត ដោយមានការចុះហត្ថលេខារបស់តំណាងគណបក្សនយោបាយ ឬ បេក្ខជនឯករាជ្យ ដែលបានចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោតនោះ ។ ការប្តឹងតវ៉ាលទ្ធផលបោះឆ្នោតត្រូវមានហេតុផលច្បាស់លាស់ និង ភស្តុតាងគាំទ្រ ដើម្បីឱ្យតុលាការអាចពិនិត្យ និង សម្រេចបានត្រឹមត្រូវ ។ ក្នុងករណីដែលតុលាការទទួលយកបណ្តឹងតវ៉ា តុលាការនឹងកោះហៅភាគីពាក់ព័ន្ធទាំងអស់ឱ្យចូលបង្ហាញភស្តុតាង និង ការពន្យល់ជាលាយលក្ខណ៍អក្សរ ឬ តាមរយៈការសាកសួរដោយផ្ទាល់មាត់ នៅក្នុងសវនាការជាសាធារណៈ ។ តុលាការត្រូវសម្រេចលើបណ្តឹងតវ៉ាក្នុងរយៈពេលមិនលើសពីប្រាំពីរថ្ងៃ គិតចាប់ពីថ្ងៃទទួលបានបណ្តឹង ដើម្បីធានាឱ្យមានភាពច្បាស់លាស់ និង ស្ថិរភាពនយោបាយ ។





៤. ការប្រៀបធៀបរវាងលទ្ធិប្រជាធិបតេយ្យ និង ព្រះពុទ្ធសាសនា

នៅក្នុងព្រះរាជាណាចក្រកម្ពុជា សាសនាគឺជាផ្នែកមួយដ៏សំខាន់នៃជីវិតរស់នៅរបស់ពលរដ្ឋចាប់តាំងពីការបង្កើតរដ្ឋខ្មែរលើកដំបូងមកម្ល៉េះ ហើយសាសនាមានតួនាទីយ៉ាងសំខាន់ក្នុងវិស័យនយោបាយ និង ជីវិតប្រចាំថ្ងៃ។ ពលរដ្ឋភាគច្រើនដែលរស់នៅក្នុងព្រះរាជាណាចក្រកម្ពុជាសព្វថ្ងៃនេះ គឺជាពុទ្ធសាសនិកជន ហើយពលរដ្ឋគឺជាគ្រឹះនៃរបបប្រជាធិបតេយ្យរបស់ព្រះរាជាណាចក្រកម្ពុជា។

❖ **អត្តាហិ (អាត្មា-ខ្លួន)** : ក្នុងពុទ្ធសាសនា លោកអ្នកស្វែងរកសច្ចធម៌សម្រាប់ខ្លួនឯងផ្ទាល់។ ខុសពីសាសនាគ្រីស្ត ពុទ្ធសាសនិកជនមិនមានមនុស្សណាម្នាក់មកសង្គ្រោះខ្លួនបានឡើយ ប៉ុន្តែគេត្រូវតែស្វែងយល់ដោយខ្លួនឯង។ ប្រជាពលរដ្ឋ ត្រូវតែចូលរួមក្នុងរបបប្រជាធិបតេយ្យ បំណងដើម្បីឱ្យរបបនេះបានប្រព្រឹត្តទៅល្អ។ លោកអ្នកជ្រើសរើសអ្នកដឹកនាំរបស់ខ្លួន តាមរយៈការបោះឆ្នោត ហើយលោកអ្នកក៏ត្រូវតែយល់ដឹងនូវអ្វីដែលរដ្ឋាភិបាលកំពុងតែធ្វើដែរ។ ព្រោះថា ប្រជាពលរដ្ឋខ្មែរ ប្រមាណជា ៨0% ទៅ ៩0% បានទៅបោះឆ្នោតក្នុងការបោះឆ្នោតកាលពីថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ១៩៩៣ , ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៩៨ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់ ឆ្នាំ ២00២ និង ការបោះឆ្នោតកាលពីថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២00៣ កន្លងទៅនេះ ហើយព្រះរាជាណាចក្រកម្ពុជា ក៏បានបង្ហាញច្បាស់ហើយដែរថា ខ្លួនមានប្រជាពលរដ្ឋ ដែលចង់ចូលរួមក្នុងដំណើរការនយោបាយនេះ។

❖ **អច្ឆាស្ថេយ្យ (យោគយល់-អត់ឱន-សណ្តោស)** : ដោយហេតុថាការត្រាស់ដឹងជាការស្វែងយល់ផ្ទាល់ខ្លួន ហើយមនុស្សម្នាក់ៗធ្វើការសម្រេចចិត្តផ្សេងៗពីគ្នា ក្នុងការស្វែងរកសច្ចធម៌របស់ខ្លួននោះ ទើបព្រះពុទ្ធទ្រង់សម្តែងថា យើងត្រូវមានការអនុគ្រោះរវាងគ្នានិងគ្នា ចំពោះទស្សនៈផ្សេងៗគ្នា និង ជំនឿផ្សេងៗគ្នា។ របបប្រជាធិបតេយ្យជំរុញ និង លើកទឹកចិត្តឱ្យប្រជាពលរដ្ឋចេះគិតដោយខ្លួនឯង ចេះបញ្ចេញមតិ និង ទស្សនៈរបស់ខ្លួន។ ក្នុងរបបប្រជាធិបតេយ្យ ប្រជាពលរដ្ឋត្រូវចេះយោគយល់ អត់ឱន សណ្តោស និង អនុគ្រោះចំពោះមតិនិងទស្សនៈដែលផ្សេងគ្នាពីមតិនិងទស្សនៈរបស់ខ្លួន។ រាល់ភាពខ្វែងគំនាខាងនយោបាយ ត្រូវដោះស្រាយដោយសន្តិវិធី (តាមសន្លឹកឆ្នោត) មិនមែនប្រើកម្លាំង ឬ អំពើហិង្សា (គ្រាប់កាំភ្លើង) ឡើយ។

❖ **តារៈ (ការគោរព-ប្រតិបត្តិ)** : ដោយយោងទៅតាមមគ្គអរិយ-សច្ចៈទាំង ៨ ដូចជាការគោរពអាយុជីវិត ធម្មៈ (ច្បាប់) និង វិន័យបព្វជិត ដែលមានសិក្ខាបទ ២២៧ គឺជាគន្លឹះសំខាន់ណាស់សម្រាប់ធ្វើការស្វែងយល់ ឬ ត្រាស់ដឹង។ បើគ្មានការគោរពទាំងនោះទេ គឺពិតជាមិនអាចបានដល់ព្រះនិព្វានឡើយ។ ក្នុងរបបប្រជាធិបតេយ្យ ប្រជាពលរដ្ឋក៏ត្រូវគោរពនូវលិខិតបទដ្ឋានគតិយុត្តនានា ដូចគ្នានឹងអ្នកកាន់ព្រះពុទ្ធសាសនាដែរ ដូចជា ការគោរពចំពោះអាយុជីវិតជាដើម។ ការគោរពច្បាប់ និង រដ្ឋធម្មនុញ្ញរបស់ប្រទេសជាបញ្ហាដ៏សំខាន់បំផុតក្នុងរបបប្រជាធិបតេយ្យ។ ជនគ្រប់រូបមានសិទ្ធិស្មើៗគ្នានៅចំពោះមុខច្បាប់ ដោយមិនគិតពីមាន ឬ ក្រឡើយ។

ហេតុអ្វីបានជាការគោរពច្បាប់របស់ជនគ្រប់រូបមានសារៈសំខាន់ក្នុងរបបប្រជាធិបតេយ្យ? ចូរគិតអំពីបញ្ហានេះទៅក្នុងរបៀបមួយនៃការធ្វើចរាចរតាមផ្លូវឯកទិស។ រថយន្តមួយបានឆ្លើសនឹងច្បាប់ចរាចរ ហើយបើកបរបញ្ច្រាស់ទិសនៅលើដងផ្លូវ ដូច្នេះ ទម្ងើរបស់គាត់អាចបណ្តាលឱ្យមានគ្រោះថ្នាក់ចរាចរ និងធ្វើឱ្យមានរបួសស្នាមដល់អ្នកដទៃ នេះក៏ព្រោះតែគាត់មិនគោរពច្បាប់ចរាចរ ហើយទង្វើដដែលនេះ អាចធ្វើឱ្យមានការកកស្ទះចរាចរ ឬ ធ្វើឱ្យមានភាពច្របូកច្របល់ថែមទៀតផង។

❖ **កម្មៈ (សកម្ម)** : យោងទៅតាមមគ្គអរិយសច្ចៈទាំង ៨ អ្វីដែលអ្នកធ្វើ គឺត្រូវតែរួមបញ្ចាំងដូវ សម្មាទិដ្ឋិ (ការយល់ឃើញត្រូវតាមសេចក្តីពិត) សម្មាសង្កប្បៈ (ការត្រិះរិះត្រូវតាមសេចក្តីពិត) សម្មាវាចា (ការនិយាយត្រូវតាមសេចក្តីពិត)។ មនុស្សមិនអាចនិយាយថាខ្លួនជាអ្នកកាន់ព្រះពុទ្ធសាសនាតែបែរជាទៅកាប់សំលាប់មនុស្ស ឬ សត្វ សម្រាប់ការត្រេកត្រអាលរបស់ខ្លួនឡើយ។ អ្នកនយោបាយជាច្រើនបានព្យាយាមជួយប្រទេសរបស់គេ ជារឿយៗ គេសន្យាតាមវិធីផ្សេងៗគ្នា។ ឧទាហរណ៍ : ព្រះសង្ឃមួយអង្គ ដែលអាចមើលឃើញនូវអំពើល្អ ឬ អាក្រក់បាន គឺអាស្រ័យដោយសកម្មភាពរបស់ព្រះអង្គផ្ទាល់។ ដូច្នេះ បើសិនជាព្រះសង្ឃអង្គនោះ ឆាន់សុរា និង គង់នៅជាមួយស្រីពេស្យាជារឿយៗ យើងនឹងដឹងថាព្រះសង្ឃអង្គនេះ មិនបានប្រព្រឹត្តតាម មគ្គ (ផ្លូវ) ឆ្ពោះទៅកាន់ការត្រាស់ដឹងឡើយ តើអ្នកនយោបាយទាំងនោះ អាចនឹងប្រព្រឹត្តដូច្នេះដែរឬទេ? ចូរលោកអ្នកស្តាប់នូវអ្វីដែលអ្នកនយោបាយទាំងនោះនិយាយ ប៉ុន្តែ សូមលោកអ្នកក៏កុំភ្លេចពិនិត្យនូវអ្វីដែលអ្នកនយោបាយទាំងនោះធ្វើផងដែរ។ មានន័យថាត្រូវពិនិត្យសកម្មភាពជាក់ស្តែង ឱ្យបានច្រើនជាងការដែលគាត់និយាយ។

❖ **បុច្ឆនៈ (សំនួរ)** : ព្រះពុទ្ធទ្រង់សម្តែងថា ឱ្យចោទសួរនូវពាក្យប្រៀនប្រដៅរបស់ទ្រង់ ដើម្បីឱ្យលោកអ្នកយល់ដឹងយ៉ាងច្បាស់លាស់ អំពីអ្វីទៅដែលហៅថា សច្ចធម៌។ ការចោទសួរខ្លួនឯង គឺជាមាគ៌ាមួយឆ្ពោះទៅដល់ការស្វែងយល់ (ការត្រាស់ដឹង)។ តើអ្នកយល់ស្របជាមួយបញ្ហានេះដែរឬទេ? ក្នុងរបបប្រជាធិបតេយ្យ ប្រជាពលរដ្ឋម្នាក់ៗ តែងតែត្រូវការសួរសំនួរផ្សេងៗគ្នាជានិច្ច។ សំនួរទាំងនោះដូចជា : តើរដ្ឋាភិបាលកំពុងធ្វើអ្វីខ្លះ? តើច្បាប់ដែលកំពុងអនុម័តដោយសភាជាតិ នឹងប៉ះពាល់ដល់រូបខ្ញុំយ៉ាងដូម្តេចខ្លះ? តើតំណាងរបស់ខ្ញុំធ្វើការបានល្អឬទេ? គោលបំណងនេះ មិនមែនស្វែងយល់ដោយខ្លួនឯងដូចព្រះពុទ្ធនោះទេ ប្រជាពលរដ្ឋត្រូវចេះអប់រំ និង ស្វែងយល់ដោយខ្លួនឯងពីនយោបាយ និង សកម្មភាពផ្សេងៗរបស់អ្នកដឹកនាំដែលជាប់ឆ្នោតរបស់លោកអ្នក។

ii. ការអធិប្បាយប្រៀបធៀបរវាងរទេះ និង លទ្ធិប្រជាធិបតេយ្យ

ព្រះពុទ្ធទ្រង់បានសំដែងឡើង អំពីរទេះមួយ និង អំពីរបៀបថា តើបុគ្គលរាល់រូបអាចសំគាល់រូបរាងរទេះទាំងមូលមួយបានដោយវិធីដូចម្តេច? ក្នុងនោះមានកង់ពីរត្រូវបានភ្ជាប់ទៅនឹងភ្លៅមួយ ដែលជាអង្គសម្រាប់ទ្រតួរទេះ។ ព្រះពុទ្ធមានពុទ្ធដិកាថា ប្រសិនបើរទេះនោះត្រូវបានគេរុះរើចេញជាផ្នែកៗ ហើយចំណែករបស់វា ត្រូវបានគេដាក់រាយប៉ាយនៅលើដី ពេលនោះ គឺពិតជាគ្មាននរណាម្នាក់អាចសំគាល់បានថា ជារទេះឡើយ។

យ៉ាងណាមិញ ប្រជាធិបតេយ្យក៏ដូចគ្នានឹងរទេះនោះដែរ។ ប្រសិនបើយើងប្រើលក្ខណៈនៃប្រជាធិបតេយ្យប្រដូចទៅនឹងផ្នែករបស់រទេះនោះ គឺសិទ្ធិមនុស្សប្រដូចទៅនឹងកង់ ការគោរពច្បាប់ គឺជាភ្លៅ និង សេរីភាពសារព័តិមាន គឺជាតួរទេះ ដូច្នេះវាជាការងាយស្រួលសម្គាល់ណាស់នៅពេលរទេះនោះនៅទម្រង់ទាំងមូល។ ប្រជាធិបតេយ្យ មិនអាចចំរើនទៅមុខបានទេ ប្រសិនបើភ្លៅរបស់វា (ការគោរពច្បាប់) ស្ថិតនៅរាយប៉ាយលើដីនោះ។



iii. សារប្រយោជន៍នៃលទ្ធិប្រជាធិបតេយ្យ

លទ្ធិប្រជាធិបតេយ្យ អាចផ្តល់សារប្រយោជន៍ចំពោះប្រជាពលរដ្ឋ និង ប្រទេសជាតិយ៉ាងច្រើនដូចជា : ការផ្លាស់ប្តូរអំណាចដោយសន្តិវិធី (ជួយទប់ស្កាត់មិនឱ្យមានសង្គ្រាមដណ្តើមអំណាចគ្នា) ជួយជំរុញឱ្យមានអភិបាលកិច្ចល្អ តម្លាភាព ការទទួលខុសត្រូវ ទប់ស្កាត់អំពើពុករលួយ ការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋទូទៅ ពលរដ្ឋមានជីវភាពធូរធារ មានសេរីភាព ប្រទេសជាតិមានស្ថេរភាព សុខដុមរមនា និង សន្តិភាព។

៨. សេចក្តីបញ្ចប់

វាមានភាពច្បាស់លាស់ណាស់ដែលថា គុណភាពនៃរបបប្រជាធិបតេយ្យ ដែលលោកអ្នកប្រាថ្នាចង់បាននោះ គឺអាស្រ័យលើកិរិតនៃការចូលរួមរបស់លោកអ្នក។ លទ្ធិប្រជាធិបតេយ្យ ទទួលជោគជ័យ គឺនៅពេលដែលពលរដ្ឋគ្រប់រូបរួមគ្នា ដើម្បីចូលរួមនៅក្នុងការគ្រប់គ្រងប្រទេសរបស់ខ្លួន។ នៅក្នុងជំពូកនេះ យើងបានឃើញខ្លះៗហើយនូវសារប្រយោជន៍ ដែលគួរអោយកត់សំគាល់យ៉ាងប្រត្យក្សនៃរបបប្រជាធិបតេយ្យ។ លោកអ្នកមិនត្រូវគិតថាគុណប្រយោជន៍ទាំងនេះ គឺជាអ្វីដែលលោកអ្នកមិនអាចទទួលបាន ដោយសារតែកាលៈទេសៈនៅក្នុងសហគមន៍ ឬ ប្រទេសរបស់លោកអ្នកឡើយ។ ក្នុងនាមជាប្រជាពលរដ្ឋនៅក្នុងរបបប្រជាធិបតេយ្យ លោកអ្នកអាចបង្កើតសារប្រយោជន៍ទាំងនោះបាន តាមរយៈការចូលរួមដើម្បីពង្រឹងលទ្ធិប្រជាធិបតេយ្យរបស់លោកអ្នក។ ទីបំផុត លោកអ្នកអាចទទួលបានសារប្រយោជន៍ទាំងនេះ ដោយសារតែលោកអ្នកបានបង្កើតវា។ លទ្ធិប្រជាធិតេយ្យ គឺជាការងារដែលត្រូវការភាពព្យាយាម ប៉ុន្តែមិនមែនមិនអាចសំរេចបាននោះទេ។ គ្រាន់តែការយល់ដឹងពីគោលការណ៍គ្រឹះនៃលទ្ធិប្រជាធិបតេយ្យ និង មានស្ថាប័នប្រជាធិបតេយ្យ គឺមិនគ្រប់គ្រាន់នោះទេ។ លោកអ្នកត្រូវធ្វើការចូលរួម។ លោកអ្នកត្រូវតែផ្លាស់ប្តូរខ្លួនឯងជាមុនប្រសិនបើលោកអ្នកចង់អោយសហគមន៍ ឬ សង្គមរបស់លោកអ្នកផ្លាស់ប្តូរ។ លោកអ្នកត្រូវធ្វើនូវអ្វីដែលត្រឹមត្រូវជាមុនប្រសិនបើលោកអ្នកចង់អោយសហគមន៍ ឬ សង្គមរបស់អ្នកធ្វើអ្វីត្រូវ។ លោកអ្នកត្រូវជឿហើយអនុវត្តចំពោះអ្វីដែលថា ពុំមាននរណាម្នាក់ស្ថិតនៅពីលើ ឬ ខាងក្រោមអ្នកឡើយ ប៉ុន្តែមនុស្សទាំងអស់ត្រូវស្មើៗគ្នា។ យោងតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និង របៀបនៃការគ្រប់គ្រងរដ្ឋរបស់ប្រទេសនេះ បានបញ្ជាក់យ៉ាងច្បាស់ថា ព្រះរាជាណាចក្រកម្ពុជាប្រកាន់របបប្រជាធិបតេយ្យបែបសភា។

របបប្រជាធិបតេយ្យ ត្រូវការថែរក្សា និង ការពង្រឹងជាប្រចាំ។ បញ្ហាប្រឈមរបស់របបប្រជាធិបតេយ្យ ទាំងពេលបច្ចុប្បន្ន និង ក្នុងពេលអនាគត អាចទទួលបានជោគជ័យ ប្រសិនបើពលរដ្ឋខិតខំពង្រឹងគោលការណ៍ទាំងឡាយនៃរបបប្រជាធិបតេយ្យ។ ដូច្នេះ លោកអ្នកត្រូវអនុវត្តយ៉ាងសកម្មចាប់ពីឥឡូវនេះតទៅ។

បំណើរឈានទៅមុខ នៃចំនួនប្រទេសដែលប្រកាន់របប ប្រជាធិបតេយ្យ នៅក្នុងពិភពលោក



- ចាប់ពីឆ្នាំ ២០០០ តទៅ អ្នកគិតថា តើមានប្រទេសប៉ុន្មានដែលនឹងដើរតាមគន្លងប្រជាធិបតេយ្យ?
- ចុងបញ្ចប់នៃសតវត្សរ៍ទី ២០ (២០០០) មានប្រទេសកាន់លទ្ធិប្រជាធិបតេយ្យប្រហែល ១២០ ប្រទេស។
- ឆ្នាំ ១៩៧៤ មានប្រទេសកាន់លទ្ធិប្រជាធិបតេយ្យ ប្រហែល ៦០ ប្រទេស។
- ដើមទសវត្សរ៍ឆ្នាំ ៧០ មានប្រទេសកាន់លទ្ធិប្រជាធិបតេយ្យ ប្រហែល ៤០ ប្រទេស។
- ឆ្នាំ ១៩៦២ មានប្រទេសកាន់លទ្ធិប្រជាធិបតេយ្យ ៣៦ ប្រទេស។
- នៅដើមសតវត្សរ៍ទី ១៩ មានប្រទេសកាន់លទ្ធិប្រជាធិបតេយ្យតែ ២០ ប្រទេស ប៉ុណ្ណោះ។

សំនួរ

១. តាមការយល់ឃើញផ្ទាល់ខ្លួនរបស់អ្នក តើប្រទេសរបស់អ្នកបានអនុវត្តប្រជាធិបតេយ្យពេញលេញដែរឬទេ? តើចំណុចណាខ្លះ ដែលអ្នកយល់ថារដ្ឋាភិបាលបានអនុវត្ត និង មិនបានអនុវត្តតាមគោលការណ៍ប្រជាធិបតេយ្យ? សូមអធិប្បាយលំអិតដោយផ្អែកលើគោលការណ៍នៃរបបប្រជាធិបតេយ្យ ។

២. តើអ្នកគិតថារដ្ឋធម្មនុញ្ញមានសារៈសំខាន់ដែរឬទេ? ប្រសិនបើសំខាន់ព្រោះអ្វី? តើផ្នែកណាខ្លះនៃរដ្ឋធម្មនុញ្ញដែលអ្នកគិតថាមានសារៈសំខាន់ជាងគេ? ព្រោះអ្វី? ចូរអធិប្បាយ ។

លំហាត់

ក្រុមប្រឹក្សាតំណាងសិស្ស

សិស្សនៅក្នុងសាលារៀនមួយ បានជ្រើសតាំងក្រុមប្រឹក្សាតំណាងខ្លួនតាមលក្ខណៈប្រជាធិបតេយ្យ ដើម្បីតំណាងផលប្រយោជន៍របស់ពួកគេក្នុងសាលារៀន។ គណៈគ្រប់គ្រងសាលាបានជូនព័ត៌មានដល់ក្រុមប្រឹក្សានោះថា ការឧបត្ថម្ភស្បៀវភៅសិក្សារបស់រដ្ឋដល់សិស្សលែងមានបន្តទៀតហើយ។ នៅក្នុងជំនួបជាមួយគណៈគ្រប់គ្រងសាលា ក្រុមប្រឹក្សាតំណាងសិស្សបានឯកភាពឱ្យគណៈគ្រប់គ្រងសាលាឈប់ផ្តល់ស្បៀវភៅសិក្សាដោយឥតគិតថ្លៃដល់សិស្ស ដោយគ្មានការពិគ្រោះយោបល់ជាមួយសិស្សទាំងអស់ទាល់តែសោះ។ ជាថ្នូរទៅនឹងការសម្រេចនេះ គណៈគ្រប់គ្រងសាលាបានឯកភាពបង្កើតឡើងនូវមណ្ឌលកីឡាថ្មីមួយសំរាប់សិស្ស។ គណៈគ្រប់គ្រងសាលាក៏បានសន្យាផ្តត់ផ្តង់ដល់សិស្សណាដែលគ្មានលទ្ធភាពទិញស្បៀវភៅអានផ្ទាល់ខ្លួនរបស់ពួកគេផងដែរ។ រួចឆ្លើយនូវសំនួរជាបន្តបន្ទាប់ដូចតទៅនេះ បើយសូមផ្តល់នូវហេតុផលចំពោះចំលើយរបស់ អ្នក។

ក. តើក្រុមប្រឹក្សាតំណាងរបស់សិស្សទទួលខុសត្រូវដល់សិស្សទាំងអស់ដែរឬទេ? ព្រោះអ្វី?

ខ. តើក្រុមប្រឹក្សាតំណាងសិស្សបានប្រតិបត្តិទៅតាមគោលការណ៍ប្រជាធិបតេយ្យដែរឬទេ? ព្រោះអ្វី?

គ. បើអ្នកជាសមាជិកក្រុមប្រឹក្សាតំណាងសិស្សវិញ តើអ្នកដោះស្រាយបញ្ហានេះដូចម្តេចដែរ?

ឃ. តើសិស្សអាចធ្វើដូចម្តេច ប្រសិនបើពួកគេមិនសប្បាយចិត្ត អំពីវិធីដែលក្រុមប្រឹក្សាតំណាងសិស្សដោះស្រាយ ?

២

ការចូលរួមរបស់យុវជនក្នុងរបបប្រជាធិបតេយ្យ



គោលបំណង

ដើម្បីអោយយុវជនយល់ដឹងពីសារៈសំខាន់នៃការចូលរួម និង តួនាទីរបស់ខ្លួនក្នុងការបើកសួយលទ្ធិប្រជាធិបតេយ្យ និងបង្ហាញអោយយុវជនយល់ដឹងពីវិធីមួយចំនួនដើម្បីអោយយុវជនមានឥទ្ធិពលនៅក្នុងសង្គម ។

១. លំនាំដើម

តាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៣៥ ចែងថា "ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិចូលរួមក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌របស់ប្រទេសជាតិ។ សេចក្តីស្នើទាំងឡាយរបស់ប្រជាពលរដ្ឋត្រូវបានទទួលការពិនិត្យ និង ដោះស្រាយយ៉ាងហ្មត់ចត់ពីអង្គការរដ្ឋ"។

ដោយហេតុថា យុវជនមានចំនួនច្រើន បើប្រៀបធៀបប្រជាពលរដ្ឋសរុបទាំងអស់ ហើយយុវជនជាអ្នកដែលមានកំលាំងខ្លាំងក្លាក្នុងការជួយអភិវឌ្ឍប្រទេសជាតិ ដូច្នេះហើយទើបការចូលរួមរបស់យុវជន ជាពិសេសគឺនៅក្នុងសកម្មភាពសង្គម និង នយោបាយ មានភាពចំបាច់បំផុត។

ជាក់ស្តែងនៅទូទាំងទ្វីបអាស៊ី ក៏ដូចជាពិភពលោកទាំងមូល យុវជនគឺជាចលករដ៏មានអំណាច និង ប្រសិទ្ធភាពបំផុតសំរាប់ធ្វើការតំរង់ទិស ក៏ដូចជាការផ្លាស់ប្តូររបបនយោបាយ។ យុវជនតែងតែធ្វើជាអ្នកដឹកនាំតំរាំជំទាស់ដ៏មានប្រជាប្រិយចំពោះបញ្ហាច្បាប់នានា ការទាក់ទាញសាធារណជនឱ្យយកចិត្តទុកដាក់ទៅលើបញ្ហាសំខាន់ៗ និង ជួនកាលពួកគេថែមទាំងបានផ្លាស់ប្តូរប្រព័ន្ធគ្រប់គ្រងរដ្ឋាភិបាលទាំងមូលថែមទៀតផង។

ក្នុងខ្លឹមសារប្រធានបទនេះ យើងនឹងបង្ហាញយុវជនទាំងអស់ ថាតើក្នុងនាមជាពលរដ្ឋល្អម្នាក់ដែលរស់នៅក្នុងរបបប្រជាធិបតេយ្យ យុវជនត្រូវចូលរួមនៅក្នុងកិច្ចការសង្គមអ្វីខ្លះ ហើយតើមានវិធីអ្វីខ្លះ ដើម្បីធ្វើឱ្យក្រុមយុវជនមានឥទ្ធិពលទៅលើតំណាង និង អ្នកដឹកនាំរដ្ឋាភិបាលរបស់ខ្លួន ។

២. និយមន័យការចូលរួម

ការចូលរួម គឺជាសកម្មភាពនៃការរួមចំណែកពាក់ព័ន្ធទៅនឹងកិច្ចការទាំងឡាយរបស់ក្រុមណាមួយ។ ក្នុងរបបប្រជាធិបតេយ្យ ប្រជាពលរដ្ឋគឺជាសមាជិករបស់ក្រុមជាច្រើន ពោលគឺពួកគេអាចជាសមាជិកនៃគ្រួសារ ភូមិ ឃុំ/សង្កាត់ ស្រុក/ខ័ណ្ឌ ខេត្ត/ក្រុង ប្រទេស សមាគម អង្គការឯកភាជ្យ ក្រុមយុវជន ក្រុមសាសនា និង គណបក្សនយោបាយណាមួយជាដើម។

នៅក្នុងក្រុមនីមួយៗ ការចូលរួមដ៏សកម្មរបស់សមាជិកនៅក្នុងសកម្មភាពផ្សេងៗរបស់ក្រុម គឺជាគន្លឹះប្រកបដោយថាមពលជំរុញឱ្យសមត្ថភាពរបស់ក្រុមមានប្រសិទ្ធភាព។ សមាជិកក្រុមមានឥទ្ធិពលយោបល់ផ្សេងៗ ដើម្បីចែករំលែកអោយគ្នាទៅវិញទៅមក។ កាលណាសមាជិកក្រុមមានលទ្ធភាពអាចចូលរួមក្នុងការអនុវត្តការងាររបស់ក្រុមកាន់តែញឹកញាប់ ពួកគេនឹងកាន់តែចង់ធ្វើជាសមាជិកក្រុមតទៅទៀត។

ក្នុងនាមជាយុវជនកម្ពុជា ការចូលរួមរបស់អ្នកអាចធ្វើឡើងតាមរយៈច្រកជាច្រើន នៅក្នុងនោះរួមមាន ការទៅបោះឆ្នោត ការឈរឈ្មោះឱ្យគេបោះឆ្នោត ការទទួលបានព័ត៌មាន ការពិភាក្សាបញ្ហា ការផ្លាស់ប្តូរគំនិតយោបល់ ការចូលរួមក្នុងការប្រជុំរបស់ក្រុមប្រឹក្សាឃុំ/សង្កាត់ និង វេទិកាសាធារណៈផ្សេងៗ ការចូលជាសមាជិកនៃអង្គការ ឬ សមាគមដោយស្ម័គ្រចិត្ត ការបង្ហាញពីបញ្ហា និង សេចក្តីព្រួយបារម្ភដែលពាក់ព័ន្ធទៅនឹងផលប្រយោជន៍រួមទៅដល់អ្នកដឹកនាំការបង់ពន្ធ និង ការគាំជាដើម ។

ការចូលរួមនៅក្នុងសកម្មភាពផ្សេងៗរបស់សង្គម គឺជាធាតុដ៏ចាំបាច់នៅក្នុងរបបប្រជាធិបតេយ្យ។ ការខកខានរបស់ពលរដ្ឋ ជាពិសេសគឺយុវជនដើម្បីចូលរួមក្នុងរបបប្រជាធិបតេយ្យជាមួយនឹងថ្នាក់ដឹកនាំ គឺហាក់ដូចជាកំពុងប្រាប់ឱ្យថ្នាក់ដឹកនាំធ្វើអ្វីតាមតែចំនើងចិត្ត។ ជារឿយៗ ការមិនចូលរួមបានផ្តល់ឱ្យរដ្ឋាភិបាលនូវអំណាចមួយ ដោយពុំមានការត្រួតពិនិត្យដែលជាហេតុនាំទៅរកការដឹកនាំតាមបែបផ្តាច់ការ ឬ បែបផ្សេងៗ នៃរដ្ឋាភិបាលអាជ្ញានិយម។ ដូចនេះ ការចូលរួមពីបុរស ស្ត្រី និង ជាពិសេស យុវជន គឺជាកំលាំងចលករមិនអាចខ្វះបាន ដើម្បីឱ្យអ្នកដឹកនាំទទួលខុសត្រូវចំពោះការងារគ្រប់ពេលវេលា។

៣. តួនាទីចូលរួមរបស់យុវជនកម្ពុជា ក្នុងការលើកស្ទួយលទ្ធិប្រជាធិបតេយ្យ

ដោយសារយុវជនមានចំនួនច្រើន បើប្រៀបធៀបនឹងពលរដ្ឋដទៃ ហើយជាងនេះទៅទៀត យុវជនគឺជាសម្បត្តិដ៏មានតំលៃបំផុតរបស់សហគមន៍ និង ប្រទេសជាតិ ដូចនេះ ដើម្បីឱ្យមានលទ្ធិប្រជាធិបតេយ្យ យុវជនកម្ពុជាគ្រប់រូបត្រូវតែ :

- អាន ជជែក និង ធ្វើការអប់រំជាមួយអ្នកដទៃទៀត ចំពោះបញ្ហាដែលកើតមានក្នុងសហគមន៍របស់អ្នក រួចហើយសរសេរអំពីបញ្ហាទាំងនេះជូនអ្នកដឹកនាំ។
- បង្កើត ឬ ចូលរួមជាមួយសមាគមឯករាជ្យ និង អង្គការ ឬ សហគមន៍នៅមូលដ្ឋានដទៃទៀត ដូចជា សមាគមយុវជននៅក្នុងឃុំ/សង្កាត់ ដោយស្ម័គ្រចិត្ត។
- ចូលរួមប្រជុំនៅក្នុងសហគមន៍ ដូចជា ការប្រជុំក្រុមប្រឹក្សាឃុំ/សង្កាត់ និង វេទិកាសាធារណៈដទៃទៀត។ ឧទាហរណ៍ បណ្តាញរបស់ក្រុមប្រឹក្សាយុវជនកម្ពុជា តែងតែចូលរួមនៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ/សង្កាត់ និង វេទិកាសាធារណៈ ដែលរៀបចំឡើងដោយអង្គការក្រៅរដ្ឋាភិបាលផ្សេងៗ ដើម្បីលើកពីបញ្ហា ឬ សេចក្តីព្រួយបារម្ភរបស់ពួកគេទៅជូនអ្នកដឹកនាំ។ យោងតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ/សង្កាត់ ពលរដ្ឋទាំងអស់មានសិទ្ធិចូលរួមក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ/សង្កាត់។
- ចុះឈ្មោះ និង ទៅពិនិត្យបញ្ជីឈ្មោះបោះឆ្នោត។ ការចុះឈ្មោះ និង ពិនិត្យបញ្ជីឈ្មោះបោះឆ្នោត នៅក្នុងប្រទេសកម្ពុជា គឺធ្វើឡើងក្នុងអំឡុងខែ តុលា ជារៀងរាល់ឆ្នាំ។
- ចូលរួមក្នុងសកម្មភាពឃោសនា ឬ សកម្មភាពផ្សេងៗ របស់គណបក្សនយោបាយ ។
- ឈរឈ្មោះឱ្យគេបោះឆ្នោត ។



- ទៅបោះឆ្នោតជ្រើសរើសតំណាងរបស់ខ្លួន និង ចូលរួមជាអ្នកស្ម័គ្រចិត្តជាមួយក្រុមដទៃទៀត ដើម្បីសង្កេតការណ៍លើការបោះឆ្នោត។
- ចូលរួមជាមួយក្រុមផ្សេងៗទៀត ដើម្បីបញ្ចុះបញ្ចូលមន្ត្រីសាធារណៈទៅលើបញ្ហាសំខាន់ៗ។
- តាមដាន និង ពិនិត្យលើសកម្មភាពរបស់មន្ត្រីជាប់ឆ្នោត។
- ជួយលើកស្ទួយការគោរពច្បាប់ សិទ្ធិ និង ការអត់ឱន។ គោរពសិទ្ធិរបស់យុវជន និងពលរដ្ឋដទៃ។
- ការពារ និង ថែរក្សារអោយបានខ្ជាប់ខ្ជួន នូវប្រពៃណីវប្បធម៌ដ៏ល្អរបស់ខ្មែរយើង។

- អភិវឌ្ឍគុណសម្បត្តិ និង វិន័យផ្ទាល់ខ្លួន ធ្វើចិត្តឱ្យទូលាយចេះអត់ឱន មានអាកប្បកិរិយាល្អ ហើយត្រូវចេះមើល និង គិតពូកឱ្យបានវែងឆ្ងាយ ។
- បណ្តុះបណ្តាលអោយបានយល់ដឹងពីគោលការណ៍នៃប្រជាធិបតេយ្យ និង សិទ្ធិមនុស្ស។ រៀនទទួលនូវអំណរសាទរជាមួយនឹងភាពអត់ធ្មត់ និង ការអត់ឱន។ ក្រុមប្រឹក្សាយុវជនកម្ពុជា ផ្តល់នូវវគ្គបណ្តុះបណ្តាលប្រភេទនេះនៅក្នុងខេត្តក្រុងចំនួន ៩ របស់ខ្លួន ចាប់តាំងពីឆ្នាំ ២០០៣ មកម្ល៉េះ។
- ចូលរួមសកម្មភាពទៅក្នុងការរៀបចំផែនការ ការអនុវត្ត និង ការវាយតំលៃចំពោះគោលនយោបាយ និង កម្មវិធីរបស់រដ្ឋាភិបាលទៅលើបញ្ហាដែលប៉ះពាល់ដល់យុវជន និង អនាគតរបស់ពួកគេទាំងនៅថ្នាក់មូលដ្ឋាន និង ថ្នាក់ជាតិ។
- ផ្តួចផ្តើមគំនិតដឹកនាំ និង បង្កើតវេទិកាយុវជន ស្តីពីលទ្ធិប្រជាធិបតេយ្យ និង ការអភិវឌ្ឍ ដោយចាប់ផ្តើមនៅថ្នាក់មូលដ្ឋានរហូតទៅដល់ថ្នាក់ជាតិ រួមទាំងព្រឹត្តិការណ៍ដទៃៗទៀត ដូចជាការប្រឡងប្រណាំងលទ្ធិប្រជាធិបតេយ្យ និង សិទ្ធិមនុស្ស។
- លើកស្ទួយឱ្យមានវប្បធម៌ប្រជាធិបតេយ្យជាមួយយុវជនទាំងថ្នាក់ជាតិ និង អន្តរជាតិ តាមរយៈប្រព័ន្ធអប់រំ និង បណ្តុះបណ្តាល កម្មវិធីផ្លាស់ប្តូរយុវជន ការទទួលស្គាល់នូវភាពចាំបាច់នៃការជជែកពិភាក្សា និង កិច្ចសហប្រតិបត្តិការ ដើម្បីលើកស្ទួយការអត់ឱន ការគោរព និង ការយោគយល់។

៤. ហេតុអ្វីបានជាការចូលរួមរបស់យុវជន មានសារៈសំខាន់ក្នុងលទ្ធប្រជាធិបតេយ្យ ?

- ការចូលរួមរបស់យុវជន ធានាថា មេដឹកនាំមិនរំលោភអំណាចតាមអំពើចិត្ត និង ធានានូវការទទួលខុសត្រូវ និង តម្លាភាពនៅក្នុងការដឹកនាំប្រទេស។
- ការចូលរួមរបស់យុវជន អាចបង្កើនប្រសិទ្ធភាពនៃការអភិវឌ្ឍប្រទេសដោយធានាថា ការសំរេចចិត្តទាំងឡាយត្រូវបានធ្វើឡើងដោយផ្អែកលើការយល់ដឹងច្បាស់លាស់អំពីបញ្ហា។ ជាមួយនឹងការចូលរួមដ៏សកម្មពីយុវជន ការដោះស្រាយបញ្ហាទាំងនោះនឹងមានលក្ខណៈសមស្របច្រើនឡើងថែមទៀតទៅនឹងតំរូវការជាមូលដ្ឋាន។
- ការសំរេចចិត្តទាំងឡាយដែលបានធ្វើដោយមន្ត្រីរដ្ឋាភិបាលមានការពាក់ព័ន្ធទៅនឹងការបែងចែកនៃធនធានសាធារណៈ ដូច្នេះ ជាមួយនឹងការចូលរួមរបស់យុវជន ការបែងចែកធនធានសាធារណៈ នឹងអាចឆ្លើយតបជាមួយនឹងតំរូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋទាំងអស់។
- ជាមួយនឹងការចូលរួមរបស់យុវជននៅក្នុងដំណើរការនៃការអនុវត្តលទ្ធិប្រជាធិបតេយ្យ មន្ត្រីរដ្ឋាភិបាលអាចបង្កើនការយល់ដឹងរបស់ខ្លួន ស្តីអំពីការចង់បានរបស់ប្រជាពលរដ្ឋ និងបង្កើននូវការគាំទ្រជាសាធារណៈ ចំពោះការសំរេចចិត្តដែលពួកគេបានធ្វើ។
- ការចូលរួមរបស់យុវជន អាចជួយអោយមន្ត្រីរដ្ឋាភិបាលគ្រប់គ្រងលើទំនាស់ទាំងឡាយនៅក្នុងប្រទេស ដោយគ្មានការជំទាស់ពីផ្នែកផ្សេងៗ នៅក្នុងប្រទេស ឬ ការបង្កឱ្យមានទំនាស់ក្នុងចំនោមក្រុមផ្សេងៗនៃប្រជាពលរដ្ឋ ឬ យ៉ាងហោចណាស់មន្ត្រីរដ្ឋាភិបាល អាចដោះស្រាយនូវទំនាស់ធំៗឱ្យបានទាន់ពេលវេលា ហើយបង្កើននូវឱកាសក្នុងការឈានទៅរកការសំរេចចិត្តមួយ ដែលគេទាំងអស់គ្នាអាចទទួលយកបាន។
- ការចូលរួមរបស់យុវជន អាចជួយបង្កើននូវការគាំទ្រជាសាធារណៈចំពោះមន្ត្រីជាប់ឆ្នោត។ ប្រសិនបើយុវជនមិនពេញចិត្តទៅនឹងមន្ត្រីជាប់ឆ្នោត ពួកគេនឹងផ្លាស់ប្តូរមន្ត្រីទាំងនោះ តាមរយៈការបោះឆ្នោតបែបប្រជាធិបតេយ្យនៅពេលក្រោយ។ ប៉ុន្តែផ្ទុយទៅវិញយុវជនអាចទទួលបាននូវការយល់ដឹងកាន់តែប្រសើរ អំពីបញ្ហាលំបាកទាំងឡាយ ដែលមេដឹកនាំ ឬ តំណាងរបស់ពួកគេកំពុងព្យាយាមដោះស្រាយ ព្រមទាំងជំរើសដ៏លំបាក ដែលមន្ត្រីជាប់ឆ្នោតត្រូវតែធ្វើការសំរេច។
- ជាមួយនឹងការចូលរួមសម្លេងរបស់យុវជន នឹងត្រូវបានគេឮ ហើយនឹងក្លាយជាផ្នែកមួយនៃការសំរេចចិត្ត ដែលអាចប៉ះពាល់ដល់ការរស់នៅរបស់ពួកគេ។ របបប្រជាធិបតេយ្យត្រូវការការចូលរួមយ៉ាងសកម្ម និង ជាប្រចាំពីប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋានទាំងអស់នៅក្នុងសង្គម។

៤. ហេតុអ្វីបានជាក្រុមយុវជនមានឥទ្ធិពលនៅក្នុងសង្គម ?

យុវជន/និស្សិតនៅក្នុងសង្គមផ្សេងៗគ្នាជាច្រើនមានគុណសម្បត្តិមួយចំនួន ដែលធ្វើអោយមានឥទ្ធិពលដល់ការផ្លាស់ប្តូរខាងនយោបាយពីព្រោះ :

- យុវជនត្រូវបានគេមើលឃើញថាជាកម្លាំងសីលធម៌នៅក្នុងសង្គម

ក្នុងបណ្តាប្រទេសជាច្រើន ទោះបីយ៉ាងណាក៏ដោយ ក៏យុវជន/និស្សិត ត្រូវបានគេមើលឃើញថាមានលក្ខណៈស្អាតស្អំជាងអ្នកឯទៀតនៅក្នុងសង្គមដែរ។ យុវជនបានទទួលការអប់រំយ៉ាងច្បាស់លាស់ និង ប្រកបដោយឧត្តមគតិទៀតផង។ យុវជនមានការព្រួយបារម្ភច្រើន អំពីថាតើប្រទេសជាតិរបស់គេនឹងក្លាយទៅជាយ៉ាងណា? ហើយយុវជនមានឆន្ទៈមោះមុត ដើម្បីធ្វើការផ្លាស់ប្តូរអំពីបញ្ហាផ្សេងៗ។ ជាទូទៅ ឧត្តមគតិនិយមនេះមានប្រជាប្រិយភាពណាស់ជាមួយផ្នែកដទៃៗទៀតនៅក្នុងសង្គម ហើយយុវជនមានអារម្មណ៍ថា ត្រូវតែអនុវត្តជាជាងគ្រាន់តែមានឧត្តមគតិ។

- តាមទស្សនាវដ្តីមួយមានការស្គាក់ស្តើរក្នុងការចាត់វិធានការប្រឆាំងតវ៉ាយុវជន

គុណសម្បត្តិមួយទៀតដែលយុវជនមាន គឺថាជារឿយៗរដ្ឋាភិបាលមិនចង់តាមសង្កត់ក្រុមសកម្មជនរបស់យុវជនទេ ហើយបញ្ហានេះ ក៏ដោយសារតែមានហេតុផលមួយចំនួនដូចខាងក្រោម :

- ជារឿយៗយុវជនត្រូវបានគេឃើញថាជា "អ្នកឆ្លាត" និង ជា "អ្នកសំរេចស្នាដៃខ្ពស់" ហើយហេតុដូច្នេះពួកគេត្រូវបានសរសើរដោយមជ្ឈដ្ឋានដទៃៗទៀតនៃសង្គម។
- ការប្រឆាំងតវ៉ារបស់យុវជន ជារឿយៗ បានទាក់ទាញនូវការចាប់អារម្មណ៍ពីប្រព័ន្ធឃោសនាជាតិ អន្តរជាតិជាច្រើន ដូច្នេះការចាត់វិធានការបង្ក្រាបទៅលើការប្រឆាំងតវ៉ាត្រូវបានរាយការណ៍ទូលំទូលាយគ្រប់ទីកន្លែង ដោយសារព័ត៌មាន។
- បណ្តាប្រទេសប្រជាធិបតេយ្យជឿជាក់ថា ប្រជាពលរដ្ឋត្រូវមានសិទ្ធិតវ៉ាដោយសន្តិវិធី ហើយការគាបសង្កត់លើការតវ៉ារបស់យុវជននឹងផ្តល់ឱ្យរដ្ឋាភិបាលនូវរូបភាពអាក្រក់លើឆាកអន្តរជាតិ។
- ការគាបសង្កត់ទៅលើយុវជនអាចបង្វែរឱ៍ពុកម្តាយរបស់គេធ្វើការតវ៉ានឹងរដ្ឋាភិបាល។
- ជាទូទៅ យុវជនជាកូនចៅនៃសមាជិករដ្ឋាភិបាល។

❖ យុវជន/និស្សិតផ្សព្វផ្សាយព័ត៌មានយ៉ាងល្បឿន

ជាក់ស្តែងក្រុមយុវជន/និស្សិតស្ថិតនៅជាមួយគ្នាជិតស្និទ្ធក្នុងបរិវេណសាលាជារៀងរាល់ថ្ងៃ។ ជាលទ្ធផលពួកគេអាចពិភាក្សាគំនិត និង ផ្សព្វផ្សាយព័ត៌មានអំពីបញ្ហាផ្សេងៗយ៉ាងល្បឿនទៅកាន់យុវជនម្នាក់ៗ។ សំខាន់ជាងនេះទៅទៀត យុវជនអាចឆ្លើយតបបានយ៉ាងល្បឿនទៅនឹងបញ្ហាផ្សេងៗហើយអាចរៀបចំអង្គប្រជុំ និង ការតវ៉ាជំទាស់ ឬ ផ្សព្វផ្សាយញត្តិបានល្បឿនជាងក្រុមដទៃៗទៀត។ ជារឿយៗ យុវជនពូកែប្រើបច្ចេកវិទ្យាថ្មីៗ ដូចជាអ៊ីម៉ែល អ៊ីនធឺណិត និង សារតាមទូរស័ព្ទ ហើយអាចផ្សព្វផ្សាយព័ត៌មានដល់មិត្តភក្តិក្នុងសាលាដទៃ ក៏ដូចជាដល់ប្រជាពលរដ្ឋក្នុងប្រទេសជាច្រើនទៀតបានយ៉ាងល្បឿនបំផុត។

❖ យុវជនមានពេលទំនេរច្រើន

ទោះបីយុវជនភាគច្រើនរវល់នឹងការរៀនសូត្រ កិច្ចការសាលា និង ការងារក្រៅម៉ោងធ្វើការក៏ដោយ ក៏កម្មវិធីពេលវេលារបស់ពួកគេអាចបត់បែនបានទៅតាមកាលៈទេសៈ។ យុវជនអាចមានពេលច្រើនជាងអ្នកដទៃៗទៀតនៅក្នុងសង្គម ដើម្បីរៀបចំអង្គប្រជុំ សិក្ខាសាលា និង ក្រុមពិភាក្សាដើម្បីជជែកអំពីបញ្ហានយោបាយ សង្គម សេដ្ឋកិច្ច និង បរិស្ថានជាដើម។ ជាពិសេស បញ្ហានេះពិតប្រាកដណាស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលយុវជនមានការមមាញឹកយ៉ាងខ្លាំងក្នុងអំឡុងពេលសិក្សានៅសាលា ដើម្បីអាចបានចូលរៀនមហាវិទ្យាល័យល្អៗ ប៉ុន្តែ នៅពេលដែលយុវជនបានចូលសិក្សានៅមហាវិទ្យាល័យហើយ គេអាចមានពេលច្រើន ដើម្បីធ្វើការស្រាវជ្រាវ និង ចូលរួមក្នុងការពិភាក្សាផ្សេងៗ ដើម្បីស្វែងរកផលប្រយោជន៍ដោយសេរី។

❖ យុវជនមានភាពក្លាហានក្នុងការតែងចម្លងនិងបន្តច

ក្នុងសង្គមភាគច្រើន ប្រជាពលរដ្ឋ ត្រូវបានគេកំណត់សេរីភាព ដើម្បីសម្តែងទៅលើជំនឿរបស់ពួកគេ ដោយសារចំណងទាក់ទងរបស់ពួកគេទៅជាមួយអ្នកដទៃៗទៀត។ ពលរដ្ឋទូទៅជាច្រើន ភ័យខ្លាចមានផលប៉ះពាល់ដល់ចៅហ្វាយនាយពួកគេ នៅឯកន្លែងធ្វើការ ភ័យខ្លាចមានផលប៉ះពាល់ដល់អ្នកដឹកនាំនយោបាយនៅមូលដ្ឋាន ម្ចាស់ផ្ទះឈ្នួល ឬ នគរបាល ប្រសិនបើពួកគេសម្តែងចេញនូវមតិនយោបាយ ដែលជំទាស់នឹងរដ្ឋាភិបាល។ យុវជនក៏មានអារម្មណ៍ថា ខ្លួនមានការគាបសង្កត់ខ្លះៗដូចគ្នាដែរ ប៉ុន្តែវាគ្រាន់តែមានកំរិតតិចជាងមនុស្សចាស់ និង អ្នកធ្វើការប៉ុណ្ណោះ។ តែពួកគេនៅតែតំរូវឱ្យមានចំណងទាក់ទងខាងវិជ្ជាជីវៈ ហិរញ្ញវត្ថុ នយោបាយ និង សង្គម ដែលរង់ចាំសំរាប់ពួកគេអោយឈានក្នុងពិភពលោកមួយ "ពិតប្រាកដ"។ ជាលទ្ធផល យុវជនច្រើនតែក្លាហានជាងគេចំពោះការសម្តែងមតិជាសាធារណៈ។

៤. វិធីមួយចំនួនដែលធ្វើឱ្យក្រុមយុវជនមានឥទ្ធិពលទៅលើសង្គម



៤.១. ការបង្កើត និង ចូលរួមក្នុងសមាគម ឬ អង្គការឯករាជ្យផ្សេងៗ

ការបង្កើត និងការចូលរួមក្នុងសមាគម ឬ អង្គការស្ម័គ្រចិត្តនានា មានសារៈសំខាន់ណាស់ចំពោះយុវជន ព្រោះជាវិធីដែលអាចធ្វើឱ្យយុវជនរួបរួមគ្នាបានរឹងមាំ ដើម្បីធ្វើឱ្យពួកគេមានឥទ្ធិពលទៅលើការសំរេចចិត្តផ្សេងៗរបស់រដ្ឋាភិបាល។ ដូចនេះក្រុមយុវជនត្រូវតែរៀបចំខ្លួនរួចជាស្រេច បើពុំដូច្នោះទេ ពួកគេនឹងមិនអាចបង្ហាញនូវខ្លឹមសារច្បាស់លាស់មួយ ដែលជាក្តីព្រួយបារម្ភរួមរបស់ខ្លួនបានទេ។ យុវជនអាចបង្កើតអង្គការផ្សេងៗគ្នាជាច្រើនរួមមាន ក្រុមធ្វើការតស៊ូមតិ ដែលអាចទាក់ទាញការយកចិត្តទុកដាក់លើបញ្ហាជាក់លាក់ ដូចជា : បញ្ហាបរិស្ថាន សុខភាព ល័ក្ខខ័ណ្ឌការងារមិនត្រឹមត្រូវ អំពើពុករលួយ ឬ ក្រុមសិក្សាស្រាវជ្រាវ ដើម្បីបង្កើនចំណេះដឹង ហើយជំរុញឱ្យមានការផ្លាស់ប្តូរគំនិតគ្នាដោយសេរីអំពីអត្ថប្រយោជន៍ និងឧបសគ្គដែលនាំឱ្យមានការរាំងស្ទះដល់ការអនុវត្តលទ្ធិប្រជាធិបតេយ្យ។ អង្គការទាំងនេះ ត្រូវមានលទ្ធភាពគ្រប់គ្រាន់ដោយខ្លួនឯងក្នុងផ្នែកមូលនិធិ ការដឹកនាំ និងត្រូវមានទីតាំងច្បាស់លាស់ ដើម្បីងាយស្រួលក្នុងការជួបជុំគ្នា។ ដូចនេះ ពួកគេនឹងមិនប្រឈមមុខចំពោះការបាត់បង់សម្លេងឡើយ ប្រសិនបើក្រុមរបស់គេមិនមានប្រជាប្រិយភាពជាមួយសាកលវិទ្យាល័យ ឬ រដ្ឋាភិបាលនោះទេ។

សកម្មជនឥស្សរជនក្នុងប្រជាធិបតេយ្យអាចប្រកាន់យកចំរង់ជាច្រើនដោយពឹងផ្អែកទៅលើបញ្ហា និង ស្ថានភាពដែលប្រឈមមុខនឹងយុវជន។ យុវជនត្រូវសំរេចដោយខ្លួនឯងថាតើដំណាក់ដែលអាចបង្កើតឡើងនូវលទ្ធផលជាវិជ្ជមានក្នុងការជំរុញឡើងនូវការពិភាក្សាឱ្យបានរស់រវើកច្រើនបំផុត និងបុព្វហេតុដែលមិនសូវគ្រោះថ្នាក់ចំពោះអ្នកចូលរួម។ វិធីទូទៅដែលត្រូវបានអនុវត្ត ដោយក្រុមយុវជននៅក្នុងបណ្តាប្រទេសជាច្រើនមាន :









ខ្ញុំមានអារម្មណ៍ថាមានសេចក្តីសុខ ប្តី ភ្ញៀវទាំងឡាយ ដែលបានមកចូលរួមក្នុងពិធីនេះ ។ ការសម្តែងរបស់ក្រុមយើងខ្ញុំ ក៏ដូចជាក្រុមដទៃទៀត ដែលបានសម្តែងនៅ

ជ.៤. ការផ្សព្វផ្សាយ

ក្រុមយុវជន/និស្សិតនឹងមានឥទ្ធិពលតែបន្តិចបន្តួចប៉ុណ្ណោះ ប្រសិនបើពួកគេមិនពង្រីកសកម្មភាពចេញទៅក្រៅឱ្យបានទូលំទូលាយទេនោះ។ យុវជន/និស្សិត ត្រូវខិតខំឱ្យបានច្រើនតាមលទ្ធភាពដែលអាចធ្វើទៅបាន ដើម្បីបញ្ចូលទស្សនៈ និង សេចក្តីព្រួយបារម្ភរបស់ខ្លួនទៅដល់ត្រប់មហាជនទូទៅ។ រាល់ការផ្សព្វផ្សាយ យុវជនត្រូវប្រាកដថា ខ្លឹមសាររបស់ខ្លួនត្រូវបានគេដឹងឮ និង បានយល់ដោយប្រជាពលរដ្ឋមួយចំនួនធំ។ វិធីមួយក្នុងចំណោមវិធីដទៃៗផ្សេងទៀត ដើម្បីធ្វើឱ្យមានការផ្សព្វផ្សាយព័ត៌មានរបស់ខ្លួនបានទូលំទូលាយ គឺតាមរយៈការបង្កើតប្រព័ន្ធឃោសនាឯករាជ្យ ដូចជា : ព្រឹត្តិបត្រ ទិន្នានុប្បវត្តិ ដែលអ្នកនិពន្ធអាចសម្តែងអំពីទស្សនៈរបស់គេ ហើយអានពីទស្សនៈអ្នកដទៃទៀត ការផ្សព្វផ្សាយតាមវិទ្យុ ពាក្យស្លោក បដា និមិត្តសញ្ញាផ្សេងៗ ផ្ទាំងរូបភាព ខិត្តប័ណ្ណ ដែលអាចជាការសរសេរការបោះពុម្ព ការសំដែង ឬ ការនិយាយ អ៊ីនធឺណេត អ៊ីម៉ែល ការផ្ញើសារតាមទូរស័ព្ទ ឬ របៀបផ្សព្វផ្សាយតាមវិធីផ្សេងៗទៀត។ យុវជន/និស្សិត ក៏ត្រូវបង្កើតទំនាក់ទំនងជាមួយប្រព័ន្ធឃោសនាបរទេស និង ក្នុងស្រុក ដើម្បីធ្វើឱ្យប្រាកដថា មតិសាធារណៈអន្តរជាតិដឹងអំពីការអំពាវនាវរបស់ខ្លួនក្នុងសកម្មភាពពង្រឹងលទ្ធិប្រជាធិបតេយ្យ។ យុវជន/និស្សិត ក៏អាចធ្វើឱ្យមានឡើងនូវការផ្ទាស់ប្តូរដោយគាំទ្រជាសាធារណៈនូវឥស្សរជននយោបាយ ឬ បេក្ខជន សំរាប់តំណែងដែលខ្លួនមានអារម្មណ៍ថាតំណាងឱ្យទស្សនៈ និងសេចក្តីប៉ងប្រាថ្នារបស់ខ្លួន។ ជាចុងបញ្ចប់ អង្គការយុវជន/និស្សិត ត្រូវជួយរៀបចំ និង បង្កើតសម្ព័ន្ធភាពឱ្យបានច្រើនជាមួយអង្គការឯករាជ្យផ្សេងៗ និង សមាគមយុវជន/និស្សិត នៅក្នុងមហាវិទ្យាល័យ ដូចជា : ក្រុមតស៊ូមតិសកម្មជនប្រជាធិបតេយ្យ និង សហជីពកម្មករ។ ល។





ជ.៥. ការរៀបចំបាតុកម្មថ្មាសាធារណៈ:

កន្លងមក ចលនាយុវជន/និស្សិតបានរៀបចំធ្វើបាតុកម្មជាសាធារណៈ ដែលបាតុកម្មខ្លះមានលក្ខណៈជាទ្រង់ទ្រាយតូច និង ភ្ជាន់ការប្រឈមមុខ ឧទាហរណ៍ : ការប្រជុំគ្នានៅកន្លែងសាធារណៈ ដែលជាកន្លែងមនុស្សប្រមូលផ្តុំគ្នា ដើម្បីស្តាប់វាគ្មិនលើកឡើងពីបញ្ហាផ្សេងៗជាដើម។ ប្រភេទខ្លះទៀតក៏អាចមានទ្រង់ទ្រាយធំ ដូចជា : ការដើរជាក្បួន ឬ ការប្រជុំមហាជននៅកន្លែងសាធារណៈធំៗ ការប្រឆាំងតវ៉ានៅខាងមុខអាគាររដ្ឋាភិបាល ដែលជាកន្លែងមន្ត្រីជាន់ខ្ពស់ជួបជុំគ្នា ការធ្វើកូដកម្មបង្អត់អាហារ រហូតដល់ការតវ៉ាជំទាស់របស់ពួកគេទទួលបានការឆ្លើយតប ការធ្វើពហិការមិនចូលរៀន ការឈរ ឬ អង្គុយនៅស្ងៀមមួយកន្លែង ជាដើម ។

ការធ្វើបាតុកម្មជាសាធារណៈ គឺត្រូវបានគេចាត់ទុកថាជាសកម្មជននិយមលទ្ធិប្រជាធិបតេយ្យ ហើយតែងតែមានប្រសិទ្ធភាពបំផុត។ ដើម្បីអោយមានប្រសិទ្ធភាព មេដឹកនាំយុវជន/និស្សិត ត្រូវតែរៀបចំផែនការធ្វើបាតុកម្មដោយប្រុងប្រយ័ត្ន ហើយត្រូវប្រកាន់គោលការណ៍អហិង្សា ទោះបីជាពួកគេជួបប្រទះការញុះញង់យ៉ាងណាក៏ដោយ ។

៣. ឧទាហរណ៍ចម្លងចំនួនស្តីអំពីយុវសកម្ម នៅក្នុងព្រះរាជាណាចក្រកម្ពុជា

ក្នុងនាមយុវជនកម្ពុជា អ្នកអាចសំរេចដោយខ្លួនរបស់អ្នកផ្ទាល់ ទៅលើរបៀបដែលអ្នកអាចរៀបចំ ដើម្បីឱ្យមានសម្លេងរួមមួយ ក្នុងចំណោមយុវជនទាំងអស់ ដើម្បីអោយក្លាយជាក្រុមមួយ ដែលមានប្រសិទ្ធភាព។ ខាងក្រោមនេះ គឺជា ឧទាហរណ៍មួយចំនួន នៃសកម្មភាពរបស់យុវជនកម្ពុជា ដែលបានធ្វើរយៈពេលកន្លងមកនេះ។



- កម្មកររាប់សិបនាក់ ដែលតំណាងឱ្យកម្មកររាប់រយពាន់នាក់ មកពីរោងចក្រផ្សេងៗនៅក្នុងព្រះរាជាណាចក្រកម្ពុជា បានរួមគ្នាបង្កើតសហជីពជាច្រើនក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះក្នុងគោលបំណងការពារសិទ្ធិ និង ផល-ប្រយោជន៍រួមរបស់កម្មករទាំងអស់។ ចាប់តាំងពីការបង្កើតសហជីពទាំងនោះមក ការទាមទាររបស់កម្មករត្រូវបានគេមើលឃើញថាមានប្រសិទ្ធភាព និង ជោគជ័យបំផុតតាមរយៈការប្រើមធ្យោបាយអហិង្សា និង ប្រជា-ធិបតេយ្យ ពីព្រោះពួកគេបានទទួលប្រាក់ប្រៃវត្សរ៍ និង លក្ខខណ្ឌការងារប្រសើរជាងមុន។

- នៅឆ្នាំ ១៩៩៨ និស្សិតរាប់ពាន់នាក់ បានប្រមូលផ្តុំគ្នាដើម្បីតវ៉ាជំទាស់ទៅនឹងលទ្ធផលនៃការបោះឆ្នោតតំណាងរាស្ត្រ។ ការតវ៉ានេះ ត្រូវបានគេមើលឃើញថា ជាបាតុកម្មដ៏ធំជាងគេ នៅក្នុងប្រវត្តិសាស្ត្រព្រះរាជាណាចក្រកម្ពុជា ហើយមានការទាក់ទាញយ៉ាងខ្លាំងចំពោះសារព័ត៌មានជាតិ និង អន្តរជាតិ។ ទោះបីជាបាតុកម្មនេះ មិនបានសំរេចគោលបំណងចុងក្រោយរបស់ខ្លួនក៏ដោយ ក៏ជាតំណាងឱ្យការរួបរួមដ៏ខ្លាំងក្លា ក្នុងចំណោមនិស្សិតខ្មែរ ដែលស្រេកឃ្លានចង់បានលទ្ធិប្រជាធិបតេយ្យ។

- នៅចុងឆ្នាំ ១៩៩៩ និស្សិតមហាវិទ្យាល័យនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ជំនាន់ទី ៣ រាប់រយនាក់ បានរួបរួម គ្នា ដើម្បីទាមទារការងារធ្វើនៅក្នុងរដ្ឋាភិបាល បន្ទាប់ពីការបញ្ចប់ការសិក្សារបស់ពួកគេ។ ជាលទ្ធផល ការទាមទារបស់ពួកគេ ត្រូវបានឆ្លើយតបដោយរដ្ឋាភិបាលកម្ពុជាពោលគឺ និស្សិតទាំងអស់ទទួលបានការងារនៅក្នុងរដ្ឋាភិបាល។

- នៅក្នុងឆ្នាំ ២000 និស្សិតរាប់រយនាក់ មកពីមហាវិទ្យាល័យ សាកលវិទ្យាល័យនានា ក្នុងរាជធានីភ្នំពេញ បានរួមគ្នាធ្វើបាតុកម្មប្រឆាំងនឹងសំណង់អនាធិបតេយ្យ ក្នុងបរិវេណវត្តចក្រអង្រែលើ។ ការតវ៉ារបស់និស្សិត បានទទួលការទាក់ទាញយ៉ាងខ្លាំងពីប្រជាពលរដ្ឋ និស្សិតសង្គមស៊ីវិល ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ព្រមទាំងមន្ត្រីរដ្ឋាភិបាល និង រដ្ឋសភាឡើតផង។ ជាលទ្ធផល អាជ្ញាធរបានរុះរើសំណង់អនាធិបតេយ្យទាំងនោះចេញ។

- រាជរដ្ឋាភិបាលអាណត្តិទី ៣ បានអនុម័តយុទ្ធសាស្ត្រ ចតុកោណរបស់ខ្លួន ដែលរួមបញ្ចូលនូវបញ្ហាអាទិភាព ចំនួន ៣ គឺ ការពង្រឹងគុណភាពអប់រំ សុខភាព និង ការងារ ដែលបានលើកឡើងដោយក្រុមប្រឹក្សាយុវជនកម្ពុជា ក្នុងអំឡុងពេលការរៀបចំវេទិកាយុវជន និង ការប្រជុំបញ្ចុះបញ្ចូលជាមួយគណបក្សនយោបាយ ដែលមានអាសនៈក្នុងសភា រួមមាន គណបក្សប្រជាជនកម្ពុជា គណបក្សហ៊្វុនស៊ិនប៉ិច និង គណបក្សសមរង្ស៊ី មុនពេលបង្កើតរដ្ឋាភិបាល។

- យុវជនរាប់រយនាក់ក្នុងខេត្តចាត់ដំបង បានចុះហត្ថលេខាលើញត្តិមួយ រួចបញ្ជូនទៅក្រុមប្រឹក្សាឃុំស្វាយចេក ដើម្បីស្នើឱ្យចាត់វិធានការយ៉ាងមានប្រសិទ្ធភាព ក្នុងការការពារបរិស្ថានតាមបណ្តោយដងស្ទឹងសង្កែ។ ជាលទ្ធផល តំណាងរបស់យុវជនត្រូវបានអាជ្ញាធរអញ្ជើញឱ្យពិនិត្យមើលតំរោងរៀបចំប្រព័ន្ធបង្ហូរទឹកស្អុយ ដែលនឹងត្រូវចាប់ផ្តើមនៅឆ្នាំ ២005។

- នៅឆ្នាំ ២004 ក្រុមប្រឹក្សាឃុំស្វាយរៀង បានចាត់វិធានការធ្វើឱ្យប្រសើរឡើងនូវបរិស្ថាននៅក្នុងទីផ្សារវាលយន្ត ដោយការដាក់ចុងសំរាមនៅជុំវិញផ្សារ និង ពន្យល់ណែនាំពលរដ្ឋកុំឱ្យនៅក្នុងផ្សារទាំងអស់ឱ្យទុកដាក់សំរាមឱ្យបានត្រឹមត្រូវ ព្រមទាំងបានចេញនូវបទបញ្ជា ចំពោះវីដេអូអាសអាភាស ដែលវិធានការទាំងនេះ ត្រូវបានធ្វើឡើងបន្ទាប់ពីក្រុមប្រឹក្សាឃុំ បានទទួលញត្តិពីយុវជនក្នុងខេត្តស្វាយរៀង។

- នៅឆ្នាំ ២004 យុវជន អាយុក្រោម ប្រជាពលរដ្ឋប្រមាណជិត ២000 នាក់ បានចុះហត្ថលេខាលើញត្តិមួយស្តីពីភាពមិនប្រក្រតីនៃការយកភាស៊ីនៅផ្សារបឹងកុក ហើយបានដាក់ជូនសមាជិកសភាមណ្ឌលកំពង់ចាម។ បន្ទាប់ពីបានទទួលញត្តិនេះ សមាជិកសភាមួយរូប បានសរសេរលិខិតជូនរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង អភិបាលខេត្ត ដើម្បីស្នើឱ្យជួយធ្វើអន្តរាគមន៍ដោះស្រាយបញ្ហានេះ។

- ក្នុងអំឡុងពេលពិភាក្សាលើថវិកាជាតិឆ្នាំ ២00៥ យុវជនជាង ៣000 នាក់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា បានធ្វើញត្តិស្នើឱ្យតំណាងរាស្ត្រទាំងអស់ ជួយតំឡើងថវិកាជាតិឆ្នាំ ២00៥ សំរាប់ចំណាយផ្នែកសុខភាព អប់រំ និង ការងារ ដែលជាតំរូវការចាំបាច់របស់យុវជន។ នៅក្នុងការប្រជុំរបស់រដ្ឋសភាសំណើរបស់យុវជន ត្រូវបានលើកឡើងដោយសមាជិកសភា ៥ រូប និង ទាក់ទាញប្រព័ន្ធផ្សព្វផ្សាយព័ត៌មានជាតិ និង អន្តរជាតិយ៉ាងខ្លាំង ដែលមិនធ្លាប់មានពីមុន។

ផ. ឧទាហរណ៍ចម្លងចំនួនស្តីអំពីយុវសកម្ម នៅជុំវិញពិភពលោក

យុវជន គឺជាឧបករណ៍ដ៏មានអំណាចបំផុត សំរាប់ធ្វើការតំរង់ទិស និង ការផ្លាស់ប្តូររបបនយោបាយដ៏មានប្រសិទ្ធភាពទូទាំងទ្វីបអាស៊ី ក៏ដូចជាទូទាំងពិភពលោក។ យុវជនរមែងជាអ្នកដឹកនាំដ៏ទាស់ដ៏មានប្រជាប្រិយភាពចំពោះបញ្ហានានា ក្នុងការទាក់ទាញឱ្យសាធារណជន យកចិត្តទុកដាក់ចំពោះបញ្ហាសំខាន់ៗ និងជួនកាលពួកគេ ថែមទាំងបានផ្លាស់ប្តូរប្រព័ន្ធគ្រប់គ្រងរដ្ឋាភិបាលទាំងមូលទៀតផង។ ខាងក្រោមគឺជាជោគជ័យរបស់យុវជននៃបណ្តាប្រទេសមួយចំនួននៅទូទាំងពិភពលោក។



- ក្រុមនិស្សិតបារាំង បានធ្វើការប្រឆាំងតវ៉ាដ៏ធំមួយក្នុងខែ ឧសភា ឆ្នាំ ១៩៦៨ ដែលបានធ្វើឱ្យកក្រើកទីក្រុងប៉ារីស និងកន្លែងជាច្រើនទៀតទូទាំងប្រទេស។ ជាលទ្ធផល ពួកគេបានបង្ខំឱ្យរដ្ឋាភិបាលតំឡើងប្រាក់ខែជាអតិបរមាដល់រដ្ឋការបារាំងទាំងអស់។

- ក្រុមនិស្សិតបានដឹកនាំការប្រឆាំងតវ៉ានៅទូទាំងសហរដ្ឋអាមេរិក ក្នុងទសវត្សរ៍ឆ្នាំ ១៩៦០ និង ១៩៧០ ដើម្បីប្រឆាំងទៅនឹងសង្គ្រាមវៀតណាម។ ការប្រឆាំងតវ៉ានេះបានធ្វើអោយសាធារណជនអាមេរិកកាំងដឹងពីទិដ្ឋភាពអវិជ្ជមាននៃការពាក់ព័ន្ធរបស់អាមេរិកនៅក្នុងប្រទេសវៀតណាម ហើយទីបំផុតបានជួយធ្វើអោយមតិពលរដ្ឋអាមេរិកកាំងជាច្រើនផ្លាស់ប្តូរ និង ជាយថាហេតុ ពួកគេបានបង្ខំអោយអ្នកដឹកនាំក្នុងទីក្រុងវ៉ាស៊ីនតោនដកខ្លួនចេញពីសង្គ្រាមវៀតណាម។

- ក្រុមយុវជន/និស្សិតនៅប្រទេសចិន បានខិតខំខ្ជះខ្ជែងទាមទារឱ្យមានលទ្ធិប្រជាធិបតេយ្យ ក្នុងអំឡុងទសវត្សរ៍ឆ្នាំ ១៩៨០។ ជាលទ្ធផល ពួកគេបានជំរុញឱ្យរដ្ឋាភិបាលទីក្រុងប៉េកាំង ជឿជាក់ក្នុងការបង្កើនភាពបើកចំហខាងសេដ្ឋកិច្ច និង បន្ថយការដាក់កំរិតខាងនយោបាយ។

- ការប្រឆាំងតវ៉ារបស់ក្រុមយុវជន/និស្សិតនៅប្រទេសថៃ អាចរយៈពេលវែងទាល់តែនឹងរបបផ្តាច់ការយោធាពុករលួយ ពិតជាមានប្រសិទ្ធភាព។ ជាលទ្ធផល ពួកគេបានផ្តួលរំលំរបបផ្តាច់ការជាស្ថាពរក្នុងឆ្នាំ ១៩៧៣។ ក្នុងឆ្នាំ ១៩៩១ ក្នុងខណៈដែលមេដឹកនាំយោធាបានធ្វើរដ្ឋប្រហារ គឺពួកនិស្សិតបានដឹកនាំការប្រឆាំងតវ៉ាជាថ្មីម្តងទៀត ហើយក្នុងរយៈពេលប៉ុន្មានឆ្នាំក្រោយមក ពួកគេបាននាំលទ្ធិប្រជាធិបតេយ្យមកដល់ប្រទេសថៃវិញ។

- សហជីពនិស្សិត **ស៊ែប៊ូណេស៊ី** បានដឹកនាំការប្រឆាំងតវ៉ាទាល់តែរបបគ្រប់គ្រងពុករលួយ **ស៊ូហាតូ** ពេញមួយទិសវត្សរ៍ឆ្នាំ ១៩៩៨។ ការប្រឆាំងតវ៉ានេះបានប្រមូលការគាំទ្រពីសមាជិកជំនាន់ទៀតនៃសង្គមឥណ្ឌូណេស៊ី និង ជាយថាហេតុ បានបង្ខំឱ្យប្រធានាធិបតី **ស៊ូហាតូ** ចុះចេញពីតំណែង ក្រោយពីការគ្រប់គ្រងផ្តាច់ការអស់បីទសវត្សរ៍មក។

- ក្រុមនិស្សិត **សូលីដាណូស៊ី** ឈ្មោះ **អុតផរ** (Otpor) បានធ្វើឧត្តុកម្មអហិង្សា ដោយមានការចូលរួមពីប្រជាពលរដ្ឋ ហើយបានផ្តួលរំលំលោកប្រធានាធិបតី **សូឡូដាន់មីឡូសេវិច** (Slobodan Milosevic) ដែលជាមេដឹកនាំផ្តាច់ការនៅយូហ្គោស្លាវី នៅថ្ងៃទី ៥ ខែ តុលា ឆ្នាំ ២០០០ ដែលចង់ក្រពុកក្នុងអំណាច ក្រោយពីមានបំណងឆ្លោតនៅថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០០០ ហើយនោះ។ ឧត្តុកម្មនេះ គឺជារឿងរ៉ាវដ៏បំផុងគេក្នុងប្រវត្តិសាស្ត្រទាំងអស់នៃការប្រឆាំងការបះបោរនៅអឺរ៉ុបខាងកើត។

- ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០០៣ គឺជាទិវាដ៏មានសារៈសំខាន់នៅក្នុងប្រវត្តិសាស្ត្រនៃប្រទេស **ហ្សកហ្ស៊ី** (Georgia)។ ពលរដ្ឋជាង ១០០០០ នាក់ បានគាំទ្រចលនា **ក្នារ៉ា** (Kmara) ដែលជាក្រុមបង្កើតឡើងដោយនិស្សិត កាលពីពីរឆ្នាំមុន បានបណ្តេញប្រធានាធិបតីផ្តាច់ការ **ហ្ស៊ីវ៉ាណាហ្ស** (Shevardnadze) អោយចុះចេញពីតំណែង។ បរាជ័យនៃរបប **ហ្ស៊ីវ៉ាណាហ្ស** បានបើកទំព័រសកវាជថ្មីសំរាប់ប្រទេសហ្សកហ្ស៊ី។

- ចលនាថ្មីមួយទៀតរបស់យុវជនមានឈ្មោះថា **ប៉ូរ៉ា** (Pora) ដែលយកតាមគំរូនៃចលនា **អុតផរ** និង **ក្នារ៉ា** បានលេចរូបរាងឡើងនៅប្រទេស **អ៊ុយក្រែន** (Ukraine) នៅខែ មីនា ឆ្នាំ ២០០៤។ ដោយការប្រើមធ្យោបាយអហិង្សា **ប៉ូរ៉ា** បានសំរេចនូវបំណងចាំបាច់របស់ខ្លួន ពោលគឺ ធ្វើឱ្យមានការបោះឆ្នោតប្រធានាធិបតីនៅក្នុងប្រទេស **អ៊ុយក្រែន** ប្រកបដោយលក្ខណៈសេរី និង យុត្តិធម៌ ជាលើកដំបូងនៅក្នុងរាកជីវិតរបស់ពួកគេ។

- បន្តពីបដិវត្តនៅក្នុងប្រទេស **ហ្សកហ្ស៊ី** និង **អ៊ុយក្រែន** បដិវត្តរប្បៀបនេះ បានកើតឡើងម្តងទៀត នៅអាស៊ីភាគកណ្តាល គឺប្រទេស **គីហ្ស៊ីស្តាន** (Kyrgyzstan) នៅខែ មីនា ឆ្នាំ ២០០៥ បាតុកម្មដ៏ធំមួយ បានកើតឡើងនៅភាគខាងត្បូងនៃប្រទេស ហើយបន្តរាលដាលដល់ទីក្រុង **ប៊ីសខិក** (Bishkek)។ ហ្វូងបាតុករ ដែលភាគច្រើនជាយុវជនក្លេងៗ បានឡោមព័ទ្ធអាគាររដ្ឋាភិបាល ហើយចុងបញ្ចប់ លោកប្រធានាធិបតី **អាកាយ៉ើវ** (Akayev) បានជំលៀសចេញពីប្រទេសជាមួយ និង គ្រួសាររបស់គាត់។

៤. សេចក្តីបញ្ចប់

ការលើកស្ទួយលទ្ធិប្រធិបតេយ្យ ត្រូវប្រឈមមុខទៅនឹងឧបសគ្គមួយចំនួន ប៉ុន្តែយុវជន/និស្សិតមិនត្រូវបណ្តែតបណ្តោយឱ្យបញ្ហាទាំងនេះរារាំងខ្លួន ក្នុងការចូលរួមធ្វើសកម្មភាពនោះឡើយ។ ដោយការប្រើវិធីផ្សេងៗ និង មធ្យោបាយដ៏មានប្រសិទ្ធភាពដទៃទៀត ដូចបានរៀបរាប់ក្នុងជំពូកនេះ រួមទាំងការរៀបចំបានល្អ ក្រុមយុវជនដែលមានការតាំងចិត្តច្បាស់លាស់ និង មានថាមពលមួយ ប្រាកដជាអាចនាំឱ្យមានការផ្លាស់ប្តូរជាវិជ្ជមាន និង ដុំកំភួនចំពោះសហគមន៍ និង ប្រទេសជាតិរបស់ខ្លួនជាមិនខាន។

យុវជនកម្ពុជាក្នុងពេលបច្ចុប្បន្ន ក៏ដូចជាពេលអនាគត គឺស្ថិតនៅក្នុងចំណោមក្រុមយុវជន ដែលមានសក្តានុពលបំផុតជាងពេលណាៗទាំងអស់។ យុវជនមានសមត្ថភាព និង អំណាចគ្រប់គ្រាន់ ដើម្បីធ្វើឱ្យមន្ត្រីជាប់ឆ្នោត និង រដ្ឋាភិបាលទាំងមូលមានការទទួលខុសត្រូវខ្ពស់ មានប្រជាធិបតេយ្យ ព្រមទាំងអាចធ្វើឱ្យមានការរីកចំរើនខាងសេដ្ឋកិច្ច សំរាប់សហគមន៍ និង ប្រទេសជាតិរបស់ខ្លួនរីតតែខ្លាំងឡើងថែមទៀត។ ដើម្បីសំរេចបាននូវចំនុចទាំងនេះ ក្នុងនាមយុវជន អ្នកត្រូវតែចូលរួមឱ្យបានយ៉ាងសកម្មបំផុត។

យុវជន ជាភ្នាក់ងារ នៃបំលាស់ប្តូរសង្គមដ៏មានប្រសិទ្ធភាព !

លំហាត់

ប្រទេស ឥណ្ឌូនេស៊ី

ក្រោយពីបានបញ្ចប់សង្គ្រាមស៊ីវិល ដែលបានអូសបន្លាយជាច្រើនឆ្នាំកន្លងមក ប្រទេស ឥណ្ឌូនេស៊ី បានកំនត់យករបបប្រជាធិបតេយ្យ ក្នុងការដឹកនាំប្រទេសជាតិ។ នៅក្នុងរដ្ឋធម្មនុញ្ញរបស់ប្រទេសនេះ មានចែងពីការផ្តល់សិទ្ធិសេរីភាពជូនប្រជាពលរដ្ឋ ក្នុងការធ្វើជាម្ចាស់លើជោគវាសនារបស់ប្រទេសជាតិរបស់ខ្លួន។ បន្ទាប់ពីត្រូវបានជ្រើសរើសដោយប្រជាពលរដ្ឋ នៅក្នុងការបោះឆ្នោត រយៈពេលប្រាំឆ្នាំកន្លងមក ការអភិវឌ្ឍប្រទេសនេះនៅតែមានការយឺតយ៉ាវដោយសារតែគេមើលឃើញថាមានអំពើពុករលួយ និង បក្សពួកនិយមនៅក្នុងជួររដ្ឋាភិបាលនោះ។ ប្រជាពលរដ្ឋភាគច្រើនមានជីវភាពក្រីក្រ ហើយបានទទួលព័ត៌មានតិចតួចបំផុតពីកិច្ចការសង្គម។ យុវជនមួយក្រុមចំនួន ៣០ នាក់ ក្រោយពីបានទទួលការបណ្តុះបណ្តាលស្តីពីលទ្ធិប្រធិបតេយ្យ និងសិទ្ធិមនុស្សពីអង្គការក្រៅរដ្ឋាភិបាលមួយមក ក៏មានបំណងចង់ឱ្យប្រទេសរបស់ខ្លួនដើរតាមគន្លងប្រជាធិបតេយ្យ ព្រោះពួកគេយល់ឃើញថា របបប្រជាធិបតេយ្យ អាចធ្វើឱ្យជីវិតរស់នៅរបស់ពលរដ្ឋទាំងអស់មានការរីកចំរើន។ ប៉ុន្តែនៅពេលដែលក្រុមយុវជនធ្វើការជំទាស់ចំពោះគំរោងការរបស់រដ្ឋាភិបាល ដែលធ្វើឡើងមិនស្របតាមតំរូវការរបស់ប្រជាពលរដ្ឋ ក្រុមយុវជនតែងតែត្រូវបានរារាំង និង មានពេលខ្លះទទួលរងការបង្ក្រាបពីអាជ្ញាធរទៀតផង តែទោះបីជាយ៉ាងណា យុវជន ទាំង ៣០ នាក់ នោះ នៅតែខិតខំធ្វើសកម្មភាពតស៊ូ ដើម្បីសំរេចគោលបំណងរបស់ខ្លួន។ ពលរដ្ឋភាគច្រើននៅក្នុងប្រទេសនេះ ពុំសូវជាខ្វាយខ្វល់ចំពោះកិច្ចការសង្គមឡើយ មិនតែប៉ុណ្ណោះមានមជ្ឈដ្ឋានខ្លះថែមទាំងបានធ្វើការរិះគន់ចំពោះសកម្មភាពរបស់ក្រុមយុវជនទាំងនោះ ដោយអ្នកខ្លះពោលថា ចំពោះរឿងនយោបាយគួរតែទុកឱ្យអ្នកដឹកនាំដោះស្រាយចុះ ចំណែកឯយើងជាពលរដ្ឋ គិតតែពីខិតខំរកអង្ករច្រកឆ្នាំងឱ្យគ្រប់គ្រាន់ទៅបានហើយ។

១. តើអ្នកយល់ដូចម្តេចចំពោះទស្សនៈ ដែលពោលថា **"ពលរដ្ឋមិនត្រូវពាក់ព័ន្ធរឿងនយោបាយ"**? ចូរពន្យល់ ។

២. តើអ្នកយល់ថា ការខំប្រឹងប្រែងរបស់យុវជនទាំងនោះ អាចទទួលបានជោគជ័យដែរឬទេ? ហេតុអ្វី?

៣. ប្រសិនបើអ្នកជាក្រុមយុវជនទាំងនោះ តើអ្នកត្រូវជ្រើសរើសវិធីណា ដើម្បីឱ្យប្រទេសរបស់អ្នកមានលទ្ធិប្រជាធិបតេយ្យ? ព្រោះអ្វី? ចូរពន្យល់ឱ្យបានក្បោះក្បាយ។

សំឆ្លុះ

១. តើប្រជាធិបតេយ្យ អាចរីងមាំបានឬទេ ប្រសិនបើគ្មានការចូលរួមយ៉ាងសកម្មពីប្រជាពលរដ្ឋ? ចូរអធិប្បាយឱ្យបានក្បោះក្បាយ និង លើកឧទាហរណ៍មកបញ្ជាក់ផង។

២. តើអ្វីខ្លះ ដែលសហគមន៍របស់អ្នកត្រូវការដើម្បីក្លាយជាសហគមន៍ប្រជាធិបតេយ្យ។ ហើយក្នុងនាមយុវជន តើអ្នកអាចធ្វើអ្វីបានខ្លះ ដើម្បីជួយពង្រឹងលទ្ធិប្រជាធិបតេយ្យនៅក្នុងសហគមន៍របស់អ្នក?

៣



អភិបាលកិច្ចល្អ





គោលបំណង

ដើម្បីអោយយុវជនយល់ដឹងពីនិយមន័យតួអង្គសំខាន់ៗ និងលក្ខណៈនៃអភិបាលកិច្ចល្អ តួនាទី និងភារកិច្ចរបស់មន្ត្រីជាប់ឆ្នោតក្នុងរបបប្រជាធិបតេយ្យ និង តួនាទីរបស់យុវជន ក្នុងការជំរុញអោយ មន្ត្រីជាប់ឆ្នោតមានការទទួលខុសត្រូវខ្ពស់។

១. អ្វីទៅជាអភិបាលកិច្ចល្អ?

អភិបាលកិច្ចល្អ គឺជាការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព នៃធនធានសាធារណៈ។ នៅក្នុងអភិបាលកិច្ចល្អ ការដោះស្រាយបញ្ហា និង ការសំរេចចិត្តផ្សេងៗ ត្រូវបានធ្វើឡើងដោយយោងទៅតាមតំរូវការ និង ផលប្រយោជន៍រួមរបស់ប្រជាពលរដ្ឋ និង សង្គមជាតិទាំងមូល។ ការយល់ដឹងពីអភិបាលកិច្ចល្អ ពិតជាមានសារៈសំខាន់ណាស់ចំពោះយុវជនក្នុងការស្វែងយល់ និង តាមដានទូរវាល់សកម្មភាពរបស់អ្នកដឹកនាំ ដើម្បីអោយការគ្រប់គ្រងប្រទេសជាតិមានប្រសិទ្ធភាពខ្ពស់។



២. តួអង្គនៃអភិបាលកិច្ច

អភិបាលកិច្ច គឺជាដំណើរការនៃការធ្វើសេចក្តីសំរេច និង ដំណើរការនៃការអនុវត្តសេចក្តីសំរេចនោះ។ ដូច្នេះ ការវិភាគនៃអភិបាលកិច្ចសង្គត់ធ្ងន់ទៅលើតួអង្គសំខាន់ៗ ដែលចូលរួមក្នុងការធ្វើសេចក្តីសំរេច និង ការអនុវត្តទៅលើសេចក្តីសំរេចដែលត្រូវបានគេបង្កើតឡើង។ រដ្ឋាភិបាល គឺជាតួអង្គមួយក្នុងចំណោមតួអង្គផ្សេងៗទៀតនៅក្នុងអភិបាលកិច្ច។ តួអង្គផ្សេងទៀតដែលពាក់ព័ន្ធក្នុងអភិបាលកិច្ច គឺអាស្រ័យទៅលើកំរិតនៃរដ្ឋាភិបាលដែលស្ថិតនៅក្នុងការពិភាក្សា។ ឧទាហរណ៍ : នៅជនបទ ផ្នែកផ្សេងៗទៀត មានដូចជា ម្ចាស់ដី សហគមន៍កសិករ អង្គការមិនមែនរដ្ឋាភិបាល វិទ្យាស្ថានស្រាវជ្រាវ អ្នកដឹកនាំសាសនា វិទ្យាស្ថានហិរញ្ញវត្ថុ គណបក្សនយោបាយ យោធា ក្រុមយុវជន ប្រជាពលរដ្ឋ។ល។ ស្ថានភាពនៅទីក្រុង គឺមានភាពស្មុគស្មាញច្រើនជាងនៅជនបទ។ បន្ថែមលើចំនុចដែលបានលើកឡើងខាងលើនៅថ្នាក់ជាតិ ប្រព័ន្ធផ្សព្វផ្សាយ ក្រុមអ្នកធ្វើការតស៊ូមតិ អ្នកផ្តល់ជំនួយអន្តរជាតិ ក្រុមហ៊ុនសាជីវកម្មពហុជាតិ។ល។ អាចដើរតួសំខាន់ក្នុងការធ្វើការសំរេចចិត្ត ឬ ក៏ធ្វើឱ្យមានឥទ្ធិពលទៅលើដំណើរការនៃការសំរេចចិត្ត។

ដូចនេះ យើងអាចនិយាយបានថា អភិបាលកិច្ច គឺរួមបញ្ចូលគ្រប់ស្ថាប័ន និង អង្គការនៅក្នុងសង្គមមួយ គឺចាប់តាំងពីរដ្ឋាភិបាលថ្នាក់ជាតិរហូតទៅដល់អ្នកជិតខាង និង គ្រួសារ។ ជាការពិតណាស់ អភិបាលកិច្ចរួមបញ្ចូលទាំងផ្នែករដ្ឋ ស្ថាប័នឯកជន សង្គមស៊ីវិល និង ប្រជាពលរដ្ឋ។ តួនាទីរបស់អភិបាលកិច្ចត្រូវបានគេផ្ទេរអោយស្ថាប័ន ឬ អង្គការសង្គមស៊ីវិល ផ្នែកឯកជន ព្រមទាំងរដ្ឋាភិបាលជាអ្នកធ្វើផងដែរ។ តួអង្គទាំងបួននៃអភិបាលកិច្ច (ពលរដ្ឋ រដ្ឋាភិបាល សង្គមស៊ីវិល និង ផ្នែកឯកជន) គឺត្រូវបានគេចាត់ទុកថា មានសារប្រយោជន៍សំរាប់ការអភិវឌ្ឍជាតិ និង មនុស្ស ហើយតួអង្គទាំងបួន ត្រូវតែធ្វើការជាមួយគ្នាយ៉ាងស្អិតរមួត (ចុះសំរុងគ្នា)។ ទាំងនោះ គឺជាស្ថាប័នដែលបានបង្កើតបទបញ្ជា ហើយជាអង្គការដែលកំនត់អនុវត្តន៍នូវគោលនយោបាយសាធារណៈ និង ឃុទ្ធសាស្ត្រសេដ្ឋកិច្ច។

៣. លក្ខណៈនៃអភិបាលកិច្ចល្អ

អភិបាលកិច្ចល្អ មានលក្ខណៈសំខាន់ ៨ យ៉ាង គឺ : ការចូលរួម ការចូលខុសត្រូវ តម្លាភាព នីតិរដ្ឋ ការឆ្លើយតបការតំរង់ទិសទៅរកមតិរួម សមធម៌ និង ប្រសិទ្ធភាព។ អភិបាលកិច្ចល្អ ធានាដល់ការកាត់បន្ថយអំពើពុករលួយ ទស្សនៈរបស់ក្រុមមនុស្សដែលមានសម្លេងភាគតិចត្រូវតែបានយកមកពិចារណា និង យោបល់របស់ក្រុមមនុស្សដែលងាយរងគ្រោះនៅក្នុងសង្គម ត្រូវបានគេបញ្ចូលនៅក្នុងការធ្វើសេចក្តីសំរេចចិត្ត។ អភិបាលកិច្ចល្អ ក៏ត្រូវឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់សង្គមក្នុងពេលបច្ចុប្បន្ន និង ពេលអនាគតផងដែរ។

❖ **ការចូលរួម :** ការចូលរួមពីសំណាក់បុរស ស្ត្រី និង យុវជន គឺជាមូលដ្ឋានគ្រឹះនៃអភិបាលកិច្ចល្អ។ ការចូលរួមអាចមានលក្ខណៈដោយផ្ទាល់ ឬ តាមរយៈស្ថាប័នតំណាង។ វាមានសារៈសំខាន់ណាស់នៅក្នុងការបង្ហាញថា ប្រជាធិបតេយ្យតំណាងមានន័យថា សេចក្តីព្រួយបារម្ភរបស់ក្រុមមនុស្សដែលងាយរងគ្រោះនៅក្នុងសង្គម ត្រូវបានគិតគូរពិចារណានៅក្នុងការធ្វើសេចក្តីសំរេចចិត្ត។ ដូចនេះ ប្រជាពលរដ្ឋត្រូវមានការរៀបចំជាអង្គការ ឬ សមាគម និង ត្រូវផ្តល់ព័ត៌មានឱ្យបានគ្រប់គ្រាន់។ នេះមានន័យថា ប្រជាពលរដ្ឋត្រូវមានសិទ្ធិសេរីភាពក្នុងការបង្កើតអង្គការ ឬ សមាគម ហើយម្យ៉ាងទៀត សង្គមស៊ីវិលត្រូវមានការរៀបចំឱ្យបានត្រឹមត្រូវ។

❖ **ការទទួលខុសត្រូវ :** ការទទួលខុសត្រូវ គឺជាតំរូវការចាំបាច់នៃអភិបាលកិច្ចល្អ។ រដ្ឋាភិបាល ផ្នែកឯកជន និង សង្គមស៊ីវិល ត្រូវតែទទួលខុសត្រូវខ្ពស់ចំពោះដៃគូដែលជាប់ពាក់ពន្ធ័ទាំងអស់។ ជាទូទៅ អង្គការ ឬ ស្ថាប័នមួយទទួលខុសត្រូវចំពោះអ្នកទាំងឡាយណា ដែលទទួលផលប៉ះពាល់ពីការសំរេចចិត្ត ឬ សកម្មភាពរបស់ខ្លួន។ ការទទួលខុសត្រូវមិនអាចអនុវត្តទៅបានឡើយ ប្រសិនបើគ្មានតម្លាភាព និង នីតិរដ្ឋ។

ការទទួលខុសត្រូវក្នុងការអនុវត្តអភិបាលកិច្ចល្អនៅថ្នាក់មូលដ្ឋាន មានន័យថា ជាការធ្វើអោយក្រុមប្រឹក្សាឃុំ/សង្កាត់ឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ និង អ្នកបោះឆ្នោតដែលបានជ្រើសរើសពួកគាត់។ ក្រុមប្រឹក្សាឃុំ/សង្កាត់ត្រូវតែធ្វើការទំនាក់ទំនងក្នុងមណ្ឌលរបស់ខ្លួន ដើម្បីជូនដំណឹងដល់ប្រជាពលរដ្ឋ អំពីកិច្ចការងារផ្សេងៗ ដោយរួមបញ្ចូលទាំងបញ្ហា ដែលធ្វើឱ្យរាំងស្ទះដល់ការងាររបស់ខ្លួនផងដែរ។ ការទទួលខុសត្រូវក៏មានន័យផងដែរថា ជាការបង្កើតលក្ខខណ្ឌដើម្បីវាស់ស្ទង់ការបំពេញការងាររបស់ក្រុមប្រឹក្សាឃុំ/សង្កាត់ ព្រមទាំងជាយន្តការ ដើម្បីធានាអោយឈានទៅដល់ស្តង់ដារការងារមួយ។ កង្វះការទទួលខុសត្រូវក្នុងការបំពេញការងារធ្វើឱ្យក្រុមប្រឹក្សាឃុំ/សង្កាត់ បាត់បង់នូវការជឿទុកចិត្តពីប្រជាពលរដ្ឋ និង អាចឈានទៅដល់ការប្រើប្រាស់ធនធានខុសគោលការណ៍ទៀតផង។ បញ្ហានេះធ្វើអោយអន្តរាយដល់សមត្ថភាពរបស់ក្រុមប្រឹក្សាឃុំ/សង្កាត់ដើម្បីទ្រទ្រង់ដល់ការអភិវឌ្ឍ និង ការផ្តល់សេវាកម្មដល់ឃុំ/សង្កាត់ទាំងមូល។ រីឯការទទួលត្រូវចំពោះហិរញ្ញវត្ថុនៅក្នុងឃុំ/សង្កាត់ មានន័យថា ធនធានហិរញ្ញវត្ថុដែលក្រុមប្រឹក្សាឃុំ/សង្កាត់មាន ត្រូវបានប្រើប្រាស់ទៅតាមវិធីដ៏មានប្រសិទ្ធភាពបំផុត។ ប្រជាពលរដ្ឋអាចធ្វើឱ្យក្រុមប្រឹក្សាឃុំ/សង្កាត់ទទួលខុសត្រូវចំពោះការប្រើប្រាស់ថវិកា និង ធនធានដទៃៗប្រកបដោយប្រសិទ្ធភាព និង និរន្តរភាព។



- **តម្លាភាព :** តម្លាភាព គឺជាភាពបើកចំហក្នុងការធ្វើសេចក្តីសំរេចផ្សេងៗ។ វាមានន័យថា ការសំរេចចិត្ត និង ការអនុវត្តត្រូវបានធ្វើឡើងនៅក្នុងលក្ខណៈស្របទៅតាមច្បាប់ និង បទបញ្ជាផ្សេងៗ ហើយវាក៏មានន័យផងដែរថា ព័ត៌មានត្រូវទៅដល់ផ្ទាល់ និង ដោយសេរីចំពោះអ្នកដែលនឹងត្រូវប៉ះពាល់ពីការសំរេចចិត្ត និង ការអនុវត្តការងាររបស់គេ។ ឧទាហរណ៍ នៅក្នុងឃុំមួយ តម្លាភាពសំដៅទៅលើភាពដែលអាចទទួលបានព័ត៌មានរបស់ប្រជាពលរដ្ឋ និង ភាពច្បាស់លាស់អំពីបទបញ្ជាផ្ទៃក្នុង និង បទបញ្ជាផ្សេងៗទៀត និង ការសំរេចចិត្តនៅក្នុងក្រុមប្រឹក្សាឃុំ/សង្កាត់ នោះ។ ការផ្តល់ឲ្យវព័ត៌មានជាក់លាក់ និង ទាន់ពេលវេលា អំពីគោលនយោបាយឃុំ/សង្កាត់មានសារៈសំខាន់លាស់សំរាប់ការធ្វើការសំរេចចិត្តរបស់ប្រជាពលរដ្ឋ។ ក្នុងន័យប្រសិទ្ធភាពការងារ សាធារណៈជនត្រូវតែទទួលបានព័ត៌មានដោយសេរី។ ដូច្នេះ ក្រុមប្រឹក្សាឃុំ/សង្កាត់ ត្រូវតែបើកចំហ និង ផ្តល់ព័ត៌មានទៅដល់ប្រជាពលរដ្ឋ ដែលទាក់ទងនឹងកិច្ចការរបស់ឃុំ/សង្កាត់ និង ការសំរេចចិត្តរបស់ក្រុមប្រឹក្សា។ តម្លាភាពនៅក្នុងការធ្វើការសំរេចចិត្ត និង ការអនុវត្តការងារ អាចកាត់បន្ថយការមន្ទិលសង្ស័យ និង រាំងចង្អិនឱ្យអំពើពុករលួយកើតឡើង។

- **ការឆ្លើយតប :** អភិបាលកិច្ចល្អ តាមទាស្រ្តីមានក្របខ័ណ្ឌច្បាស់ត្រឹមត្រូវ ដែលត្រូវបានគេអនុវត្តប្រកបដោយសុក្រឹតធម៌ និង មិនលំអៀង។ ម៉ឺងវិញ ក៏តំរូវឱ្យមានការការពារយ៉ាងពេញលេញចំពោះសិទ្ធិមនុស្សផងដែរ ជាពិសេសគឺ មតិភាគតិច និង ជនជាតិភាគតិច។ ការអនុវត្តច្បាប់ប្រកបដោយយុត្តិធម៌ តំរូវឱ្យមានតុលាការមួយបែកឥរាជ្យ និង កងកំលាំងនគរបាលមិនលំអៀង និងមិនពុករលួយ។

- **ភាពឆ្លើយតប :** អភិបាលកិច្ចល្អ តំរូវឱ្យស្ថាប័ន និង ដំណើរការនៃកិច្ចការទាំងអស់ព្យាយាមបំរើ និង ឆ្លើយតបដល់ប្រជាពលរដ្ឋទាំងអស់ នៅក្នុងពេលវេលាសមស្របមួយ។ ឧទាហរណ៍ នៅពេលដែលពលរដ្ឋធ្វើជាសំណើនានាទាក់ទិនទៅនឹងបញ្ហា និង សេចក្តីព្រួយបារម្ភ ដែលបានកើតមាននៅក្នុងសហគមន៍គាត់ អ្នកដឹកនាំត្រូវតែធ្វើការដោះស្រាយឱ្យបានទាន់ពេលវេលា និង ប្រកបដោយប្រសិទ្ធភាពខ្ពស់។

❖ **ការតម្រង់ទិសទៅរកមតិរួម :** នៅក្នុងអភិបាលកិច្ចល្អ មានតួអង្គជាច្រើនជាអ្នកធ្វើសេចក្តីសំរេចចិត្តលើបញ្ហាអ្វីមួយ ហើយតួអង្គនីមួយៗ មានគំនិតផ្ទាល់របស់គេរៀងៗខ្លួន។ អភិបាលកិច្ចល្អ តំរូវឱ្យតួអង្គទាំងនោះចេះសម្របសម្រួលផលប្រយោជន៍ផ្សេងៗគ្នានៅក្នុងសង្គម ដើម្បីឈានទៅដល់ការព្រមព្រៀង ដោយឈរលើអ្វីដែលជាផលប្រយោជន៍ប្រសើរបំផុតនៅក្នុងសហគមន៍ទាំងមូល និងមធ្យោបាយ ដើម្បីសំរេចបានផលប្រយោជន៍ទាំងនោះ។ វាតំរូវឱ្យមានទស្សនៈវិស័យទូលំទូលាយ និង វែងឆ្ងាយទៅលើអ្វីដែលជាតំរូវការសំរាប់ការអភិវឌ្ឍដោយចីរភាព និង របៀបដើម្បីសំរេចគោលបំណងនៃការអភិវឌ្ឍនោះ។ វាអាចកើតឡើងលុះត្រាតែមានការយល់ដឹងពីប្រវត្តិសាស្ត្រ វប្បធម៌ និង បរិបទសង្គម ឬ សហគមន៍ ហើយគំនិតទាំងនេះ ត្រូវបានប្រមូលរួមគ្នាដើម្បីបង្កើតចេញជាមតិទូទៅមួយ។

❖ **សមធម៌ / ការទទួលបានផលប្រយោជន៍ :** សុខមាលភាពសង្គមអាស្រ័យទៅលើការធានាថា សមាជិករបស់សង្គមទាំងអស់ទទួលបានផលប្រយោជន៍ពីការរីកចំរើនរបស់សង្គមដោយមិនត្រូវបានគេកាត់ផ្តាត់ចេញពីសង្គម។ នេះគឺតំរូវឱ្យតួអង្គទាំងអស់មានឱកាសស្មើៗគ្នា ដើម្បីបញ្ចេញនូវទស្សនៈ គំនិត និង សេចក្តីព្រួយបារម្ភរបស់ពួកគេ។

❖ **ប្រសិទ្ធភាព :** អភិបាលកិច្ចល្អ មានន័យថា រាល់ដំណើរការ និងស្ថាប័នទាំងឡាយបង្កើតលទ្ធផល ដែលឆ្លើយតបនឹងតំរូវការរបស់សង្គមដោយប្រើប្រាស់ឱ្យបានត្រឹមត្រូវនូវធនធាន ដែលពួកគេមាន។ ប្រសិទ្ធភាព នៅក្នុងបរិបទអភិបាលកិច្ចល្អ ក៏ក្តៅបផងដែរចំពោះការប្រើប្រាស់ប្រកបដោយនិរន្តរភាពនៃធនធានធម្មជាតិ និង ការការពារបរិស្ថាន។



៤. សារប្រយោជន៍នៃអភិបាលកិច្ចល្អ

អភិបាលកិច្ចល្អ បានផ្តល់នូវសារៈប្រយោជន៍មួយចំនួនសំរាប់ប្រជាពលរដ្ឋ និង ប្រទេសជាតិ ដូចជា : បង្កើនគុណភាពនៃរដ្ឋបាលសាធារណៈ ការកាត់បន្ថយនូវបែបបទការិយាល័យធិបតេយ្យ ការអនុវត្តប្រកបដោយប្រសិទ្ធភាពនៃការសំរេចចិត្តរបស់រដ្ឋាភិបាល ប្រសិទ្ធភាពនៃរដ្ឋាភិបាលនៅក្នុងការផ្តល់សេវាសាធារណៈ ស្ថេរភាពនយោបាយ ឯករាជ្យភាពនៃតុលាការ មានភាពទុកចិត្តចំពោះប្រព័ន្ធយុត្តិធម៌ មានចំនុកចិត្តចំពោះសមត្ថភាពរបស់អាជ្ញាធរក្នុងការការពារទ្រព្យសម្បត្តិ ប្រសិទ្ធភាពក្នុងការប្រឆាំងអំពើពុករលួយ ជាប្រទេសដែលមានការទាក់ទាញសំរាប់មុខជំនួញ រដ្ឋាភិបាលមានតម្លាភាព និង ការទទួលខុសត្រូវ មានយុត្តិធម៌សង្គម និង វិបុលភាព និយាយដោយខ្លីអភិបាលកិច្ចល្អ នាំមកនូវប្រសិទ្ធភាពនៃការគ្រប់គ្រង ទីតិរដ្ឋ និង ភ្លានអំពើពុករលួយ។

៥. តួនាទី និង ភារកិច្ចរបស់មន្ត្រីជាប់ឆ្នោត

ខាងក្រោមនេះជាតួនាទីភារកិច្ច និង ការទទួលខុសត្រូវមួយចំនួនរបស់ក្រុមប្រឹក្សាឃុំ/សង្កាត់ និង តំណាងរាស្ត្រដែលត្រូវបំពេញ :

៥.១. តួនាទីរបស់ក្រុមប្រឹក្សាឃុំ/សង្កាត់

ក្រុមប្រឹក្សាឃុំ/សង្កាត់ តំណាងឱ្យប្រព័ន្ធគ្រប់គ្រងថ្មីនៅមូលដ្ឋាន ដែលមានន័យថា ប្រជាពលរដ្ឋក្នុងឃុំ/សង្កាត់ គឺជាចៅហ្វាយនាយ ហើយក្រុមប្រឹក្សាឃុំ/សង្កាត់ ត្រូវតែមានការទទួលខុសត្រូវចំពោះការគោរព និង អនុវត្តបទបញ្ជានានា។ សព្វថ្ងៃនេះ ក្រុមប្រឹក្សាឃុំ/សង្កាត់ មានភារកិច្ចសំខាន់បំផុតក្នុងការបំរើសុខមាលភាពរបស់ប្រជាពលរដ្ឋជាបឋម គឺមិនមែនដើម្បីបំរើសុខមាលភាពផ្ទាល់ខ្លួនរបស់ពួកគាត់ ឬ គណបក្សរបស់ពួកគាត់ឡើយ។ ក្រុមប្រឹក្សាឃុំ/សង្កាត់អាចរកមូលនិធិផ្ទាល់របស់ខ្លួនផងដែរ តាមរយៈការប្រមូលពន្ធតាមមូលដ្ឋានថ្លៃឈ្នួល ឬ ការផាកពិន័យផ្សេងៗ។ មូលនិធិនេះអាចជាពន្ធលើទ្រព្យសម្បត្តិ ថ្លៃឈ្នួលសំចត ឬ ថ្លៃជួលអាគាររបស់រដ្ឋាភិបាលផ្សេងៗ។

- **សមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់ :** សមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់ ត្រូវបានជ្រើសរើសដោយអ្នកបោះឆ្នោត ដើម្បីឱ្យមើលការខុសត្រូវលើប្រតិបត្តិការគ្រប់គ្រងរដ្ឋបាលឃុំ/សង្កាត់ទាំងអស់ និង តាក់តែងបទបញ្ជា និងគោលនយោបាយថ្មីសំរាប់ឃុំ/សង្កាត់។ បទបញ្ជា និងគោលនយោបាយនេះ ត្រូវតំណាងឱ្យផលប្រយោជន៍ដ៏ប្រសើរបំផុតរបស់ប្រជាពលរដ្ឋមូលដ្ឋាន។

- **មេឃុំ/ចៅសង្កាត់ :** មេឃុំ/ចៅសង្កាត់ មានតួនាទីចំពោះការអនុវត្តសេចក្តីសំរេចរបស់ក្រុមប្រឹក្សាឃុំ/សង្កាត់។ មេឃុំ/ចៅសង្កាត់ គឺជាបេក្ខជនលើគេក្នុងបញ្ជីឈ្មោះរបស់គណបក្សដែលទទួលសម្លេងឆ្នោតបានច្រើនបំផុតក្នុងការបោះឆ្នោតក្រុមប្រឹក្សាឃុំ/សង្កាត់។ មេឃុំ/ចៅសង្កាត់ មានជំទប់/ចៅសង្កាត់រងចំនួន ២នាក់ ជាជំនួយការ។

- **ជំទប់/ចៅសង្កាត់រង :** ជំទប់/ចៅសង្កាត់រង ត្រូវជួយមេឃុំ/ចៅសង្កាត់ក្នុងការអនុវត្តភារកិច្ច ដែលត្រូវបានប្រគល់ឱ្យពួកគេ ដូចមានចែងក្នុងច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ/សង្កាត់។ ជំទប់ទី១/ចៅសង្កាត់រងទី១ ត្រូវជួយមេឃុំ/ចៅសង្កាត់ លើបញ្ហានានា ទាក់ទងនឹងការងារសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ។ ជំទប់ទី២/ចៅសង្កាត់រងទី២ ត្រូវជួយ មេឃុំ/ចៅសង្កាត់ លើបញ្ហានានា ទាក់ទងការងាររដ្ឋបាល សង្គមកិច្ច សេវាកម្ម និង សណ្តាប់ធ្នាប់សាធារណៈ។

- **ស្មៀនឃុំ/សង្កាត់ :** ស្មៀនឃុំ/ចៅសង្កាត់ មានភារកិច្ចជួយឃុំ/សង្កាត់លើការងារផ្សេងៗ និង ក្នុងការធានានិរន្តរភាពនៃការងាររដ្ឋបាលនៅក្នុងឃុំ/សង្កាត់របស់ខ្លួន។ ស្មៀនឃុំ/សង្កាត់ត្រូវស្ថិតនៅក្រោមការដឹកនាំរបស់ក្រុមប្រឹក្សាឃុំ/សង្កាត់។ ស្មៀនឃុំ/សង្កាត់អាចចេញលិខិតបញ្ជាក់ធ្វើអត្រានុកូលដ្ឋាន ប្រមូលស្ថិតិ និង រក្សាទុកឯកសាររដ្ឋបាលនានា។ ស្មៀនឃុំ/សង្កាត់ ត្រូវបានតែងតាំងដោយក្រសួងមហាផ្ទៃ។

៤.២. តួនាទី និង ភារកិច្ចរបស់សមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់

សមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់មានតួនាទីលើកស្ទួយ និងការពារអភិបាលកិច្ចល្អ ដោយការប្រើប្រាស់នូវធនធាន ដែលមាន ដើម្បីសំរេចបាននូវតំរូវការចាំបាច់របស់ឃុំ/សង្កាត់ សំរាប់ផលប្រយោជន៍រួមរបស់ប្រជាពលរដ្ឋ និង គោរពចំពោះផលប្រយោជន៍ជាតិ ឱ្យស្របទៅតាមគោលនយោបាយរបស់រដ្ឋ។ ពាក់ព័ន្ធទៅនឹងការងារនៅមូលដ្ឋាន សមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់ មានតួនាទីដូចតទៅ :

- រៀបចំការប្រជុំប្រចាំខែរបស់ក្រុមប្រឹក្សាឃុំ/សង្កាត់ជាសាធារណៈ និងមានលក្ខណៈប្រជាធិបតេយ្យ។
